ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៣ ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០១០ លក់តម្លៃ ១០០០រៀល តែប៉ុណ្ណោះ លេខ ៣២

## មាតិកា



យុវវ័យសម័យ ទំនើបនិយាយអំពី តម្រូវការសម្ភារៈ ទំព័រ ៥



ប្រជាពលរដ្ឋអាច ប្រើប្រាស់ថាមពល កកើតឡើងវិញ? ទំព័រ ៩



ស្នាដៃថ្មីរបស់ សិល្បករខ្មែរ ទំព័រ ១៧

# តែងតាំងលោកអភិបាលឧបត្ថម្ភកព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ



លោកអូលីវីយេ ផ្មិតហាស្លេ ត្រូវតែងតាំងជាអភិបាលឧបត្ថម្ភករបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញកាលពីថ្ងៃទី ២០ មីនាកន្លងទៅ នៅសាលាបច្ចេកទេសដុនបូស្កូ សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ។ គ្រីស្តបរិស័ទរាប់ពាន់នាក់មកពីព្រះសហគមន៍កាតូលិកទាំងបីភូមិភាគក្នុងប្រទេសកម្ពុជា និងតំណាងសាសនានានា ចូលរួមយ៉ាងអធិកអធម។ ទំព័រទី១០_១១




កម្មវិធីវិទ្យុ



**អេម៉ានូអែល** សំឡេងពីព្រះសហគមន៍កាតូលិក !

ភ្នំពេញ : FM 102.5 Mhz ម៉ោង២:០០-៣:០០ រាល់រសៀលថ្ងៃសុក្រ
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:៣០ រាល់យប់ថ្ងៃសៅរ៍
សៀមរាប : FM 102.5 Mhz ១០:០០-១១:០០ រាល់ថ្ងៃសៅរ៍
កំពង់ធំ : FM 88.5 Mhz ម៉ោង ១២:៣០-១:៣០ ថ្ងៃសៅរ៍ថ្ងៃត្រង់
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ
ក្រុងព្រះសីហនុ : FM 107.5 Mhz ម៉ោង៥:០០-៦:០០ រសៀលថ្ងៃសៅរ៍
កំពត : FM 93.25 Mhz ម៉ោង ៥:០០-៦:០០ រសៀលថ្ងៃសៅរ៍

April-2010.qxd 6/10/2010 2:55 PM Page 2

# រូបថតប្រចាំខែ



Photo : L. Sovanna

លោកអូលីវីយេ ផ្ទិតហស្ដេ ដែលទើបទទួលពិធីតែងតាំងក្លាយជាអភិបាលឧបត្ថម្ភកនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទទួលស្វាគមន៍ការអបអរសាទរបស់សម្ដេចទេព វង្ស សម្ដេចព្រះសង្ឃរាជគណៈមហានិកាយកាលពីថ្ងៃទី២០ ខែមីនា នៅសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈដុនបូស្កូ រាជធានីភ្នំពេញ។



Photo : L. Sovanan

លោកអភិបាលអូលីវីយេ ផ្ទិតហស្ដេ ទទួលដោយអំណរសម្ដេច ប៊ូ គ្រី សម្ដេចព្រះសង្ឃរាជខាងគណៈធម្មយុត្តនៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា



Photo : S. Philong

លំនៅដ្ឋានប្រជាពលរដ្ឋ ១៧៨ខ្នង ដែលជាប់ខាងត្បូងវត្តនាគវ៉ន រាជធានីភ្នំពេញ ត្រូវបានអគ្គិ-ភ័យឆាបឆេះខ្ទេចខ្ទី។ **(ឆ្វេង)**

អគ្គីភ័យកើតឡើងថ្ងៃទី៨ មីនា ក្រៅពីលំនៅដ្ឋានអគ្គីភ័យបំផ្លាញកុដិព្រះសង្ឃ១០ និងបន្ទប់ស្នាក់នៅនិស្សិត ២១ដែរ។ **(ស្ដាំ)**



Photo : S. Philong



Photo : S. Philong

គ្រោះអគ្គីភ័យនេះត្រូវបានអាជ្ញាធរមូលដ្ឋានអះអាងថា វាបណ្ដាលមកពីទុស្សេចរន្តអគ្គីសនីក្នុងលំនៅដ្ឋានមួយ ហើយរាលដាលតៗគ្នា។ ប៉ុន្តែប្រភពមួយទៀតអះអាងថា វាបណ្ដាលមកពីផ្ទុះហ្គាសទៅវិញទេ។



Photo : S. Philong

ការបាញ់កាំជ្រួច BM សាកល្បងរបស់កងយុទ្ធពលខេមរភូមិន្ទនៅកំពង់ឆ្នាំង កាលពីថ្ងៃទី៤ មីនា។

# វិចារណកថា

## “បងប្អូនពិតជាបានរស់ឡើងវិញ រួមជាមួយព្រះគ្រីស្តមែន!” (កូឡូស ៣:១)



លោកប៉ូលរឿង ឆត្រឆ័យ អ្នកសម្របសម្រួលមណ្ឌលផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក (CSC)

បុណ្យចម្លងដែលជាបុណ្យធំ និងសំខាន់ជាងគេនៃសាសនាគ្រីស្ត បានឈានមកដល់ហើយ ។

ខែមុននេះ ព្រះសហគមន៍កាតូលិកក៏បានឆ្លងព្រឹត្តិការណ៍ដ៏សំខាន់មួយ គឺពិធីអភិសេកតែងតាំងលោកអភិបាលថ្មីនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ។ ពិតមែនហើយ អត្ថន័យបុណ្យនេះក៏បានដាស់តឿនយើង និងលោកអភិបាលថ្មីដែរថា ព្រះសហគមន៍កំពុងតែងើបឡើងវិញពីសេចក្តីស្លាប់ ដោយរស់ឡើងវិញរួមជាមួយព្រះគ្រីស្ត ។

គ្រីស្តបរិស័ទ និងព្រះសហគមន៍ទទួលអត្ថន័យរបស់បុណ្យចម្លងក្នុងជីវិតជានិច្ចគឺថា “ព្រះគ្រីស្តបានរងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញយ៉ាងណា យើងគ្រីស្តបរិស័ទនឹងរងទុក្ខលំបាក ហើយក៏មានជីវិតឡើងវិញ រួមជាមួយព្រះអង្គយ៉ាងនោះដែរ” ពោលគឺបើគ្មានឈើឆ្កាង គ្មានការរស់ឡើងវិញ ។ គ្មានការរងទុក្ខលំបាក ក៏គ្មានជីវិតថ្មី ។ បុណ្យចម្លងបង្រៀនយើងថា មុនយើងស្រមៃភាពសប្បាយយើងត្រូវឆ្លងកាត់ការពិបាកជាមុនសិន ដូចជាមុនពេលយើងបានការងារធ្វើ យើងត្រូវតែពិបាកស្វះស្វែងរកសិន ។ មុនពេលយើងមានជីវិតគ្រួសារល្អយើងត្រូវលះបង់ឱ្យគ្នាទៅវិញទៅមកសិន ។ នៅមុនយើងជាសះស្បើយពីជំងឺ យើងទទួលការវះកាត់ ឬទទួលទានថ្នាំមុនសិនជាដើម ។

ជីវិតរបស់មនុស្ស តែងឆ្លងកាត់ពេលវេលា ។ បើសិនយើងបញ្ចូលអត្ថន័យបុណ្យចម្លង ថា ចូលរួមជាមួយព្រះយេស៊ូ ពិតជាយើងឆ្លងផុតសេចក្តីស្លាប់ជាមិនខាន ។ គួរឱ្យសោកស្តាយ ! ពីព្រោះមានមនុស្សជាច្រើនមិនយល់អត្ថន័យនេះ ហើយគ្រីស្តបរិស័ទខ្លះក៏ខ្វះការពិចារណានៅត្រង់ចំណុចនេះដែរ លង់គំនិតហើយរអ៊ូរទាំ ត្អូញត្អែរ តែរឿងអភ័ព្វវាសនារបស់ខ្លួនឯង ។

សន្តប៉ូលក៏បានរំឭកយើងថា គ្រីស្តបរិស័ទត្រូវរស់ឡើងវិញជាមួយព្រះគ្រីស្ត គឺបញ្ចូលជីវិតរបស់យើងផ្ញើលើព្រះអង្គទាំងស្រុងដោយប្រឹងប្រែងឱ្យអស់លទ្ធភាពរបស់ខ្លួន ជីវិតរស់ឡើងវិញនឹងក្លាយជារូបរាងជាមិនខាន ។ **រីករាយបុណ្យចម្លង...!**







**ការិយាល័យព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

Tel/Fax : (855) 23 224 120;

E-mail : csccambodia@gmail.com

Website : www.catholiccambodia.org

អ្នកសម្របសម្រួល : លោកប៉ូលរឿង ឆត្រឆ័យ ។ ប្រធាន : លោកលី សុវណ្ណា ។


Licence ១៨៣ ពម.ប្រក. / ២៥-មិថុនា-២០០៧

## កម្មវិធីវិទ្យុព្រះសហគមន៍កាតូលិក

### អ្នកចូលរួមកម្មវិធីអេម៉ានូអែល “សម្លេងពីព្រះសហគមន៍កាតូលិក” ខែមេសា

-ថ្ងៃអាទិត្យទី១ (០៤ មេសា) : លោកអភិបាលភូមិភាគកាតូលិកកំពង់ចាម អន់តូនី សាមី ស៊ូសែរាជ មកក្រុមសាសនទូតទីក្រុងប៉ារីស។

-ថ្ងៃអាទិត្យទី២ (១១ មេសា) : បងស្រីសុជាតិ មកក្រុមគ្រួសារស្រលាញ់ព្រះឈើឆ្កាង នៃព្រះសហគមន៍កាតូលិកក្រចេះ។

-ថ្ងៃអាទិត្យទី៣ (១៨ មេសា) : លោកបូជាចារ្យ អុន សុន មកពីព្រះសហគមន៍កាតូលិក តំបន់កំពត ភូមិភាគភ្នំពេញ។

-ថ្ងៃអាទិត្យទី៤ (២៥ មេសា) : បងប្រុសផាន ប៊ុរី និស្សិតទេវវិទ្យាល័យ សន្តយ៉ូហានម៉ារី វិយ៉ាណេ នៅភ្នំពេញ។

### “ខ្ញុំត្រូវការអ្នក” ខែមេសា (FM 99.5 Mhz ចន្ទ,អង្គារ ម៉ោង១០-១១ព្រឹក)

ថ្ងៃទី០៥ មេសា : ភ្លើងស្នេហ៍យុវវ័យ។ ថ្ងៃទី០៦ មេសា : ត្រៀមខ្លួនហើយឬនៅសម្រាប់ពិធីចូលឆ្នាំ ?។ ថ្ងៃទី១២ មេសា : យុវវ័យ និងគ្រឿងស្រវឹងពេលចូលឆ្នាំខ្មែរ។ ថ្ងៃទី១៣ មេសា : យុវវ័យ និងល្បែងពេលចូលឆ្នាំខ្មែរ។ ថ្ងៃទី១៩ មេសា : ផ្តើមស្នេហ៍យ៉ាងណា ? (ចេះសាងស្នេហ៍ដោយត្រឹមត្រូវ)។ ថ្ងៃទី២០ មេសា : ព្យាបាលរបួសស្នេហ៍។ ថ្ងៃទី២៦ មេសា : តាមស្នេហ៍។ ថ្ងៃទី២៧ មេសា : ស្រលាញ់អ្នក !!!។ សូមបញ្ជាក់ថា ប្រធានបទទាំងនេះ នឹងមានការចូលរួមបកស្រាយពីវាគ្មិន ដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់។ **សូមកុំភ្លេចតាមដាន!**

# សេដ្ឋកិច្ច

## សមាគមសន្សំសាមគ្គីចំណេញ ៤លានរៀល

**ខាន់ ភីរម្យ**

សមាគមតូចមួយនៅក្នុងព្រះសហគមន៍កាតូលិកផ្សារតូច អះអាងថា ខ្លួនបានរកប្រាក់ចំណេញប្រមាណ៤ លានរៀល កាលពីឆ្នាំ២០០៩។

លោកប៉ូលរឿងឆត្រឆ័យ បូជាចារ្យមួយរូបនៅព្រះសហគមន៍ផ្សារតូច មានប្រសាសន៍ថា សមាគមសន្សំប្រាក់សាមគ្គីកំពុងដើរតួនាទីយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះសហគមន៍តាមរយៈការលើកកម្ពស់ និងជំរុញឱ្យសមាជិកចេះសន្សំប្រាក់ និងអាចផ្តល់ជាប្រាក់កម្ចីសម្រាប់សមាជិកនៅក្នុងករណីត្រូវការទុនបន្ទាន់មួយនៅក្នុងការប្រកបរបររកស៊ីចិញ្ចឹមជីវិត ។

លោកមាសពុទ្ធី សមាជិកក្រុមសន្សំប្រាក់ មានប្រសាសន៍ថា គាត់បានក្លាយជាសមាជិករបស់ក្រុមសន្សំប្រាក់នេះតាំងតែពីបង្កើតដំបូង ហើយមកដល់ពេលនេះ គាត់អាចនឹងខ្ចីប្រាក់បានចំនួន១ម្តង និងមានប្រាក់សន្សំ នៅក្នុងនោះចំនួនប្រមាណ ២លានរៀល ហើយមកដល់ពេលនេះ។ លោកបានបញ្ជាក់ថា: "កាលពីឆ្នាំទៅពេលម៉ូតូខ្ញុំខូច អត់អីរត់ម៉ូតូ ខ្ញុំបានខ្ចីលុយពីសមាគម ៥០០០០០រៀល យកទៅជួសជុល កុំអីខ្ញុំអត់មានអ្វី រកស៊ីចិញ្ចឹមគ្រួសារ និងឱ្យកូនទៅរៀនបានទេ"។



Photo : ChatChey

លោកស្រីសាំង យុទ្ធ សមាជិកក្រុមសន្សំប្រាក់នេះមួយរូបទៀតក៏បានឱ្យដឹងថា សមាគមនេះអាចផ្តល់ឥណទានជាមួយនិងការប្រាក់ទាបជាង ធៀបបណ្តាប្រភពទុននានាក្នុងប្រទេសកម្ពុជា។ លោកស្រីបានមានប្រសាសន៍បញ្ជាក់ថា : "ខ្ញុំអាចខ្ចីលុយពីសមាគមដោយមិនចាំបាច់របស់ធានាជាមួយនឹងអត្រាការប្រាក់ត្រឹមតែ១% ក្នុងមួយខែតែប៉ុណ្ណោះ ខណៈដែលការប្រាក់ពីកន្លែងផ្សេងខ្លះ គេទារយករហូតដល់ទៅ ៤ ឬ៥% នៅក្នុងមួយខែក៏មាន"។

តាមប្រសាសន៍របស់បូជាចារ្យឆត្រឆ័យ ក្រៅពីមានសេវាកម្មផ្តល់ប្រាក់កម្ចី និងសន្សំនោះ សមាគមសន្សំប្រាក់សាមគ្គី មានផ្តល់សេវាកម្មមួយចំនួនទៀតផងដែរ ដូចជាការផ្តល់វិភាគទានទៅដល់អ្នកទទួលមរណភាព។ ដោយឡែក សម្រាប់អ្នកសន្សំប្រាក់វិញ គឺគាត់ទទួលបានការប្រាក់ជាមធ្យម នៅក្នុងមួយឆ្នាំ ៣% ។

លោកឆត្រឆ័យ ក៏មានប្រសាសន៍ថា: "ជាមួយនឹងសេវាកម្មនេះឆ្នាំទៅសមាគមសន្សំប្រាក់សាមគ្គីអាចរកប្រាក់ចំណេញប្រមាណជា ៤លានរៀល"។

### សមាគមសន្សំប្រាក់សាមគ្គី

លោកប៉ូលរឿង ឆត្រឆ័យ បូជាចារ្យអ្នកសម្របសម្រួលសមាគមនេះ មានប្រសាសន៍ថា សមាគមនេះបានចាប់កំណើតឡើងកាលពីចុងឆ្នាំ២០០៦ ជាមួយនឹងសមាជិកត្រឹមតែ ៣០ នាក់ ហើយមានប្រាក់សន្សំត្រឹមតែ ១៧០០០០ រៀលប៉ុណ្ណោះ តែវាបានរីកចម្រើនជាលំដាប់។ លោកបន្តថា មកដល់ពេលនេះសមាគមមានសមាជិករហូតដល់១៧០នាក់ និងមានប្រាក់សន្សំនៅធនាគារចំនួន ១៦លានរៀល និង ១១៤៥៨ដុល្លារ និងប្រាក់សន្សំជាគណនីមានកាលកំណត់នៅធនាគារ ៣២លានរៀល និង ៦៥០០ដុល្លារ ហើយនិងកំពុងផ្តល់ប្រាក់កម្ចីដល់សមាជិកចំនួន ១៦លានរៀល និង៨១៨ដុល្លារ។

សូមបញ្ជាក់ថា សមាជិករបស់សមាគមទាំងអស់អាចបើកគណនីសន្សំប្រាក់ក្នុងសមាគមបានជាមួយនឹងប្រាក់សន្សំត្រឹមតែ ១០០០រៀល តែប៉ុណ្ណោះ នៅក្នុងមួយសប្តាហ៍។

# សុខភាព

## អាសន្នរោគគឺជាជំងឺមួយយ៉ាងកាចសាហាវដែលត្រូវប្រុងប្រយ័ត្ន

**ជាត សំភី**

លោកហែម សុខហន វេជ្ជបណ្ឌិតនៃមន្ទីរពេទ្យកុមារជាតិ មានប្រសាសន៍ថា:

អាសន្នរោគជាជំងឺមួយកាចសាហាវ។ មេរោគដែលបង្កជំងឺនេះឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់តាមរយៈដៃប្រឡាក់ និងចាប់កាន់ចំណីអាហារ។

រោគសញ្ញាជំងឺអាសន្នរោគ គឺរាគ។ ប៉ុន្តែវាមានសភាពហាក់ដូចជាធ្ងន់ធ្ងរជាងរាគធម្មតា និងធ្វើឱ្យរាងកាយទ្រុឌទ្រោមខ្លាំង។ ចំពោះកុមារមានអាយុតិចជាង១៦ខែ យើងឃើញថា បង្ហើយគេផតភ្នែកខូង និងគ្មានទឹកភ្នែក។ គេក្អួតខ្លាំងណាស់ដូចបាញ់កាំជ្រួចអ៊ីចឹង។ កុមារស្រេកទឹកខ្លាំងណាស់ តែផឹកបានដោយលំបាកហើយស្បែកពោះគេឡើងជ្រួញ។




Photo : DR

លាមករបស់កុមារចាប់ផ្តើមឡើងរាងដូចជាគ្រាប់អង្ករ។ កុមាររាគតែពីរ ឬបីដង គេក៏ចាប់ស្លក់ ដូចយើងរាគធម្មតា៣០ដង។ កុមារមានអាការៈរមួលក្រពើនិងទឹកនោមតិច។ ជីពចរគេកាន់តែខ្សោយ។ បេះដូងគេក៏លោតកាន់តែញាប់។ ក្នុងលក្ខណៈនេះបើយើងមិនបានបង្គ្រប់ជាតិទឹកទេនោះ កុមារអាចស្លាប់បាន នៅក្នុងរវាងតែ៣ ទៅ៤ម៉ោងប៉ុណ្ណោះ។ ចំពោះមនុស្សចាស់វិញមានរោគសញ្ញាដូចគ្នាដែរ។

សញ្ញាដែលយើងគួរតែចាប់អារម្មណ៍ចំពោះជំងឺអាសន្នរោគ គឺការរាគធម្មតា។ ប៉ុន្តែមានសញ្ញាខ្វះជាតិទឹកធ្ងន់ធ្ងរតែក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ រីឯមនុស្សចាស់ក៏មិនខុសពីកូនក្មេងដែរ បើសិនជាគ្មានការបង្គ្រប់ជាតិទឹកទេ ៣ម៉ោង គាត់នឹងស្លាប់។

នៅពេលអាសន្នដូច្នេះ អ្នកជំងឺត្រូវទៅកាន់មន្ទីរពេទ្យជាបន្ទាន់។ ប៉ុន្តែទៅមន្ទីរពេទ្យដែលអាចព្យាបាលសេរ៉ូមបាន និងជិតជាងគេបំផុត។

ដើម្បីការពារអាសន្នរោគ អនាម័យរស់នៅ ជាប្រការសំខាន់ ជាពិសេសត្រូវលាងដៃនឹងសាប៊ូ មុនបរិភោគអាហារ និងក្រោយបន្ទោរបង់រួច។

April-2010.qxd 6/10/2010 2:55 PM Page 5






Photo : S. Philong

# យុវវ័យសម័យទំនើបនិយាយអំពីតម្រូវការសម្ភារៈ

**ខាន់ ភីរម្យ**

ម៉ូតូ សម្លៀកបំពាក់ គ្រឿងអលង្ការ ទូរស័ព្ទនិង ម៉ាស៊ីនកុំព្យូទ័រ សុទ្ធសឹងជាតម្រូវការយ៉ាងចាំបាច់ សម្រាប់យុវជនសម័យថ្មី ដើម្បីបំពេញនូវក្តីបំណង ប្រាថ្នារបស់ពួកគេ ។

ទេស សារ៉ា ជាយុវនិស្សិតឆ្នាំទីមួយ នៃសាកលវិទ្យាល័យឯកជនមួយ ហើយទើបតែមានវ័យត្រឹម ១៩ឆ្នាំ ក៏បានឱ្យដឹងថា សម្រាប់រូបគេ តម្រូវការចាំបាច់បំផុតនៅពេលនេះ មានម៉ូតូនិងម៉ាស៊ីនកុំព្យូទ័រ ហើយទូរស័ព្ទក៏ជាតម្រូវការចាំបាច់ផងដែរ ។ សារ៉ាបន្តថា បើសិនជាមិនមានសម្ភារៈទាំងនេះទេ រូបគេលំបាកណាស់ក្នុងការសិក្សា និងទំនាក់ទំនងផ្សេងៗជាមួយមិត្តភក្តិ ក៏ដូចជាអាណាព្យាបាល ។ សារ៉ាក៏បានបញ្ជាក់ថា : ˝ទូរស័ព្ទយើងអាចខ្ចីពីពួកម៉ាក ឬបងប្អូនដើម្បីទាក់ទងគ្នា ។ ប៉ុន្តែសម្រាប់ម៉ូតូ ហើយនិងម៉ាស៊ីនកុំព្យូទ័រ គឺខ្ញុំមិនអាចអត់បាននោះទេក្នុងការសិក្សារបស់ខ្ញុំ˝ ។

តាមការអះអាងរបស់សារ៉ា កត្តាដែលធ្វើឱ្យរូបគេជៀសមិនផុតអំពីតម្រូវការនូវសម្ភារៈទាំងអស់នោះ គឺដោយសារតែពេលវេលា និងការសិក្សា និងទំនាក់ទំនងក្នុងសង្គម ។ សារ៉ាបានឱ្យដឹងថា ប្រសិនបើយើងមានទូរស័ព្ទ យើងអាចទំនាក់ទំនងគ្នាងាយស្រួល និងលឿន ហើយសម្រាប់ម៉ាស៊ីនកុំព្យូទ័រវិញនោះ សម្រាប់ទុកធ្វើការងារសាលាផ្សេងៗ ដូចជា (**Assignment**) ជាដើម ។ ចំណែកម៉ូតូ គឺជាយានជំនិះចាំបាច់សម្រាប់ធ្វើដំណើរ ។

សារ៉ាបាននិយាយថា: ˝អត់ម៉ូតូម៉េចបាន ! បើខ្ញុំត្រូវរៀនសកលវិទ្យាល័យផង រៀនភាសាផង និងឆ្លៀតរៀនជំនាញផ្សេងៗទៀត ។ រីឯសាលាវិញ គឺនៅឆ្ងាយៗពីគ្នា ។ ហើយកុំព្យូទ័រវិញ រឹតតែអត់មិនបាន ពីព្រោះសរសេរដៃឥឡូវ គ្រូអត់យកទេ គាត់ចង់បានបោះពុម្ពពីកុំព្យូទ័រ ˝ ។

ចំណែកយុវនារីមួយរូបទៀតដែលយើងសូមពុំបញ្ចេញឈ្មោះបានឱ្យដឹងថា គាត់ក៏ត្រូវការសម្ភារៈដូចជាសារ៉ាផងដែរ ដើម្បីបំពេញតម្រូវការនៅក្នុងការសិក្សា ។ តែទោះបីជាយ៉ាងណាក៏ដោយ តម្រូវការរបស់គាត់ ហាក់ដូចជាលើសពីសារ៉ាបន្តិច គឺនៅត្រង់សម្លៀកបំពាក់ និងគ្រឿងលំអរផ្សេងៗ ។

យុវនារីរូបនេះ បានបញ្ជាក់បន្ថែមថា : ˝ជាតិជានារី បើសិនយើងស្លៀកសម្លៀកបំពាក់មិនសមរម្យ ហើយខ្វះគ្រឿងតុបតែងកាយខ្លះៗទៀត គឺដូចជាយ៉ាងម៉េចមិនដឹងទេ˝ ។

កញ្ញាបានឱ្យដឹងថា: ˝សម្លៀកបំពាក់ឥឡូវមួយ សម្រាប់យ៉ាងហោចណាស់ក៏ ១0ដុល្លារដែរ ចុះនៅសម្ភារៈផ្សេងៗទៀត ។ តម្រូវការនេះ ក៏មានតម្លៃថ្លៃគួរសមដែរ សម្រាប់ប្រជាពលរដ្ឋដែលក្រីក្រ˝ ។

ពាក់ព័ន្ធនឹងបញ្ហានេះ លោកតុង សុប្រាជ្ញជាអ្នកជំនាញដែលធ្វើការជាមួយនឹងយុវជន បានអះអាងថា សម្ភារៈទាំងនោះ វាពិតជាតម្រូវការដែលយុវ-ជន និងយុវនារីត្រូវការហើយ ។ ប៉ុន្តែនៅក្នុងករណីដែលយើងមិនទាន់មានលទ្ធភាព ។ យើងគួរតែចេះរៀបចំផែនការរបស់ខ្លួនដើម្បីបានវា ហើយកុំឆ្លៀតឱកាសប្រើប្រាស់មធ្យោបាយខុស ដើម្បីទទួលបាននូវសម្ភារៈទាំងអស់នោះ ។

លោកបានអះអាងថា : ˝សម្ភារៈគឺជាតម្រូវការដែលសំខាន់ តែយើងកុំយកតម្លៃរបស់យើងទៅប្តូរដើម្បីយកសម្ភារៈអស់ទាំងនោះ˝ ។

លោកក៏បានឱ្យដឹងថា កន្លងមកដើម្បីទទួលបានសម្ភារៈទាំងអស់នោះ យុវជននិងយុវនារីមួយចំនួនគិតខុស ហើយប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីបំពេញសេចក្តីត្រូវការនេះ ។ ប៉ុន្តែនេះក៏មិនមែនជាដំណោះស្រាយទេ ដំណោះស្រាយគឺសន្សំសំចៃចេះស្វែងរកការងារធ្វើក្រៅម៉ោង ទើបជាការល្អ ។

## កសិកម្ម

# វិធីសាស្ត្របង្កាត់ពូជក្រូចពោធិ៍សាត់

**កសិករ លេខ ៩៤**

កសិករឃុន សុភាព រស់នៅភូមិដប់បាត ឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ បានផ្តល់បទពិសោធន៍ល្អ ក្នុងការបង្កាត់ក្រូចពោធិ៍សាត់ ដូចតទៅនេះ :

**ឧបករណ៏ និងសម្ភារៈ**

ដើម្បីបង្កាត់ក្រូច យើងគឺត្រូវការឧបករណ៏ និងសម្ភារៈមួយចំនួនមានដូចជា: កូនកាំបិតចុងស្រួច ។ ដង្កាប់កាត់ជាដើម ។ខ្សែសម្រាប់ចង់នៅពេលយើងបង្កាត់រួច និងខ្សែនីឡុងសម្រាប់ចង និងរុំគល់ក្រូចពេលគាស់យកទៅផ្សាំមុននឹងយកកូនទៅដាំ ។

**បច្ចេកទេសបង្កាត់**



Photo : S. Angkeasath

ក. ការដាំកូនទម្រ: យើងជ្រើសរើសនូវកូនក្រូចឆ្មារអាយុបានពី៦ខែ ទៅ ១ឆ្នាំ គេអាចយកវា ទៅបង្កាត់បាន ។ យើងជ្រើសរើសមែកក្រូចពោធិ៍សាត់ យកទៅបង្កាត់ នៅលើដើមទម្រ ប្រភេទដើមណាដែលមានមែកថ្លោសល្អ ។ យើងជ្រើសរើសនូវមែកដែលមានសំបកពណ៌ខៀវចាស់ និងស្លឹកថ្លោសល្អ ។

ខ. វិធីបង្កាត់ : គឺយើងយកកាំបិតមុតស្រួចទៅចៀរសំបកដើមក្រូចឆ្មារដល់សាច់ក្នុងទំហំប៉ុនពន្លកភ្នែក ( ៣០សង្ទីម៉ែត្រ) ។ ការចៀរ ធ្វើឡើងកម្ពស់ ៣,៥-៤,៥តឹក ពីគល់ (ធ្វើដូច្នេះ ដើម្បីជៀសវាងការកើតឡើងនូវបញ្ហា ដូចជា ជំងឺផ្សិតដែលវាកើតឡើងតាមរយៈការស្រោចទឹក និងភ្លៀង ដែលអាចខ្ទាតពីដីទៅប៉ះនឹងដើម) ។ យើងចៀរនូវពន្លកដើមក្រូចពោធិ៍សាត់ មានទំហំប្រវែងជា ៣០សង្ទីម៉ែត្រ លៃយ៉ាងណាឱ្យមានទំហំប៉ុនកន្លែងដែលចៀរគល់ទម្រ( ចៀរយកភ្នែក គឺកន្លែងគល់ស្លឹក ដែលថ្លោសល្អ) ។ បន្ទាប់ពីចៀរបានហើយ គឺយើងយកទៅបិទនៅលើប្រឡោះ ចៀរដើមទំរ( ក្រូចឆ្មារ) ។ បន្ទាប់មក យើងយកខ្សែនីឡុងរុំ នៅលើមុខដែលបិទឱ្យជិតកុំឱ្យចូលខ្យល់ ។ ការធ្វើដូច្នេះ គឺដើម្បីឱ្យពន្លកនិងដើមស៊ីសាច់គ្នា ។ ក្រោយពីបង្កាត់បានរយៈពេល ១២-១៥ថ្ងៃ ពេលសង្កេតឃើញសំបកនោះ វាមានពណ៌ខៀវនោះ ការបង្កាត់ទទួលបានលទ្ធផល ។

ក្រោយអំពីរក្សាទុកនៅលើដើម បានរយៈពេល ១អាទិត្យមក ។ ប្រសិនបើវាមិនមានលក្ខណៈណាប្រែប្រួលទេ យើងអាចកាត់ដើមផ្នែកខាងលើចេញ ដោយទុកចម្ងាយ៣០-៤០សង្ទីម៉ែត្រ ពីភ្នែកសាករួចលាបខ្លាញ់គោពីលើមុខកាត់ដើម្បីការពារនូវជំងឺឆ្លង ។ លុះកន្លងមកក្រោយពីការកាត់ដើមផ្នែកខាងលើចេញហើយ ត្រូវរក្សាទុកនៅលើថ្នាលរយៈពេល ១អាទិត្យទៅ១០ថ្ងៃ ទៀតបើវាដុះល្អនោះ ។

## បរិស្ថាន

# ទំនប់វារីអគ្គីសនីស្ទឹងតាតៃបើកការដ្ឋាន

ទំនប់វារីអគ្គិសនីនៅស្ទឹងតាតៃ ដែលមានតម្លៃវិនិយោគចំនួន ៥៤០លានដុល្លារ បានត្រូវបើកឱ្យដំណើរការសាងសង់ នៅក្រោមវត្តមានរបស់ឯកឧត្តមស៊ុយ សែម រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកាលពីថ្ងៃទី២៩ ខែមីនា កន្លងទៅ ។

ឯកឧត្តម ស៊ុយ សែម បានមានប្រសាសន៍ថា ទំនប់វារីអគ្គិសនីនេះនឹងដំណើរការថាមពលអគ្គិសនីទាំងស្រុងនៅក្នុងឆ្នាំ២០១៤ ខាងមុខ ។

ក្រុមហ៊ុនដែលទទួលសិទ្ធិវិនិយោគលើទំនប់វារីអគ្គិសនីនេះជាក្រុមហ៊ុនចិន មានឈ្មោះ ឆាយណាណាត្យូណាល់ ហេវី ម៉ាស៊ីន ណារី ខបផូរេសិន ។

លោកលូ វេនចន ជាប្រធានក្រុមហ៊ុនឆាយណាណាត្យូណាល់ ហេវី ម៉ាស៊ីនណារី ខបផូរេសិន បានអះអាងថា ទីតាំងរបស់ទំនប់វារីអគ្គិសនីនេះ មានចម្ងាយប្រមាណជា៥០គម ពីទីរួមខេត្តកោះកុង ។ ទំនប់នេះវានឹងដើរ ហើយផលិតថាមពល ជាមួយនិងតួប៊ីនបីគ្រឿង ដោយតួប៊ីននីមួយៗអាចផលិតថាមពលចំនួន ៨២មេហ្គាវ៉ាត់ ហើយវាដំណើរការសាងសង់នឹងរួចរាល់នៅក្នុងឆ្នាំ២០១៣ ។

ប្រភពថាមពលដែលផលិតចេញពីទំនប់វារីអគ្គិសនីនេះ អាចធ្វើការផ្គត់ផ្គង់មកកាន់ រាជធានីភ្នំពេញ ខេត្តកោះកុង និងខេត្តព្រះសីហនុ ។

ពាក់ព័ន្ធនឹងគម្រោងការកសាងទំនប់វារីអគ្គិសនី អ្នកអភិរក្សផ្នែកបរិស្ថាន ក៏បានស្នើសុំឱ្យមានការប្រយ័ត្នប្រយែង និងធ្វើសិក្សាឱ្យបានល់អិតចំពោះការសាងសង់ទំនប់វារីអគ្គិសនី ដោយសារក្តីបារម្ភពីផលប៉ះពាល់ដល់បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ។ កន្លងមកផលប៉ះពាល់បរិស្ថាន ដែលសហគមន៍និងសង្គមស៊ីវិលដែលបានធ្លាប់ជួបប្រទះ និងយល់ដឹងអំពីទំនប់វារីអគ្គិសនី រួមមាន ដូចជាការបាក់ច្រាំងការតាំងទីលំនៅថ្មីរបស់ប្រជាជន ការផ្លាស់ប្តូរនូវប្រព័ន្ធអេកូឡូស៊ីនៃប្រភពទឹក និងបំផ្លាញធនធានវប្បធម៌នៅក្នុងតំបន់ រួមនិងផលប៉ះពាល់ទៅដល់ប្រភពធនធានសេដ្ឋកិច្ចរបស់ប្រជាជនផងដែរ ។

**ខាន់ ភីរម្យ**

April-2010.qxd 6/10/2010 2:55 PM Page 7



# សកលភូមិន្ទវិចិត្រសិល្បៈបណ្ដុះបណ្ដាលអ្នកថតរូបអាជីព

**ជាត សំភី**



Photos : S.Philong

យុវនិស្សិតកំពុងផ្ចិតពិនិត្យកាម៉េរ៉ាយ៉ាងផ្ចិតផ្ចង់ក្នុងវគ្គបណ្ដុះបណ្ដាលថតរូបនៅឯសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

លើកនេះ អាចចាត់ទុកជាលើកទីមួយហើយក្នុងរយៈពេល១០ឆ្នាំកន្លងមក ដែលវគ្គបណ្ដុះបណ្ដាលអ្នកថតរូបអាជីព ត្រូវបានបើកធ្វើឡើងនៅសាលាភូមិន្ទវិចិត្រសិល្បៈក្រុងភ្នំពេញ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១០ កន្លងទៅនេះ ហើយក៏គ្រោងនឹងបញ្ចប់ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១០។

កម្មវិធីនេះបានដំណើរការទៅ ក្រោមគំនិតផ្តួចផ្តើមរបស់មជ្ឈមណ្ឌលវប្បធម៌បារាំងសហការជាមួយនិងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

លោកអាឡាំង អាណូដេ ជានាយកមជ្ឈមណ្ឌលវប្បធម៌បារាំងបានមានប្រសាសន៍បញ្ជាក់ថា យើងបង្កើតវគ្គបណ្ដុះបណ្ដាល ថតរូបនេះឡើង ពីព្រោះយើងគិតថា រូបថតគឺជាទម្រង់នៃការបង្ហាញព័ត៌មាន ដែលប្រកបដោយភាពទូលំទូលាយ។ ហើយការថតរូបមិនមែនជាការងាយស្រួលទេ គឺទាមទារឱ្យមានការសិក្សា។ លោកបន្ថែមថា: "ខ្ញុំសង្ឃឹមថានៅពេលបញ្ចប់វគ្គនិស្សិតនឹងមានស្នាដៃល្អប្រសើរយកទៅតាំងពិព័រណ៍ នៅមហោស្រពរូបថត ដែលរៀបចំឡើងនាចុងឆ្នាំនេះ ដោយមជ្ឈមណ្ឌលវប្បធម៌បារាំងដោយមានការចូលរួមពីអ្នកថតរូបល្បីៗទាំងជាតិ និងអន្តរជាតិជាច្រើន"។

វគ្គថតរូបនេះ គឺមានសិស្សចូលរួមចំនួន ៨នាក់ ដែលជានិស្សិតឆ្នាំទីពីរ ទីបី និងទីបួន ប្រចាំសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដែលភាគច្រើនមកពីផ្នែកវិចិត្រកម្ម និងការតុបតែងលំអ(អគារ)។ រីឯគ្រូដែលមកណែនាំ មានលោកច័ន្ទ វិចារិន សាស្ត្រាចារ្យផ្នែកសិល្បៈសូនរូបនៅក្នុងសាលាភូមិន្ទវិចិត្រសិល្បៈ ហើយក៏ធ្លាប់ជាអ្នកថតរូបអាជីពម្នាក់ដែរ ព្រមទាំងលោកសុវណ្ណ ភីឡុង គឺជាអ្នកថតរូបនៅសារព័ត៌មានភ្នំពេញប៉ុស្តិ៍។

លោកសុវណ្ណ ភីឡុង មានប្រសាសន៍ថា ពួកគេគឺជាសិស្សនៅឯសាលាវិចិត្រសិល្បៈ។ ដូច្នេះពួកគេមានមូលដ្ឋានសិល្បៈស្រាប់ ដែលលោកគិតថា ការស្វែងយល់អំពីការថតរូបមានភាពងាយស្រួលដែរសម្រាប់ពួកគេ។ លោកបន្តថា: "ខ្ញុំគ្រាន់តែជាអ្នកណែនាំម្នាក់ ដែលធ្លាប់ប្រឡូកមុន លើការថតរូប។ ដូច្នេះខ្ញុំក៏ចង់ចែករំលែកចំណេះដឹងមួយចំនួនដែលខ្ញុំបានរៀនទៅកាន់សិល្បៈករជំនាន់ក្រោយ។ ខ្ញុំគិតថា នេះក៏គឺជាឱកាសល្អមួយសម្រាប់អ្នកសិក្សាដែរ ពីព្រោះជំនាញថតរូបនេះនៅមានតិចនៅឡើយ។

# "ពីមុនខ្ញុំគិតថា ការថតរូប គ្រាន់តែចុចៗ ជាការស្រេច"

ចំពោះលក្ខខណ្ឌសម្រាប់វគ្គថតរូបនេះ គឺតម្រូវឱ្យនិស្សិត ដែលចាប់អារម្មណ៍ចង់រៀននូវវគ្គថតរូប យករូបថតអ្វីក៏បាន ម្នាក់៥សន្លឹក យកមកសម្រាំងជ្រើសរើស។ បេក្ខជនណា ដែលមានរូបថតល្អជាងនឹងបានចូលរៀនវគ្គនេះ។

លោកស៊ិន មករា គឺជាបេក្ខជនដែលមានរូបថតខ្លួនជាប់ចំណាត់ថ្នាក់ក្នុងចំណោមបេក្ខជនទាំង ៥៨នាក់ និងជានិស្សិតឆ្នាំទីបីផ្នែកវិចិត្រកម្មគំនូរទំនើបនាសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនេះ។លោកក៏មានប្រសាសន៍ថា: "ខ្ញុំមានការចាប់អារម្មណ៍លើវគ្គថតរូប ដោយសារវាជាសិល្បៈមួយស្រដៀងទៅនឹងការគូរគំនូររបស់ខ្ញុំផងដែរ។ កាលពីមុនខ្ញុំគិតថាការថតរូបនេះ វាដូចជាមិនលំបាកណាស់ណាទេ។ យើងគ្រាន់តែចង់បានកន្លែងណា គ្រាន់តែចុច គឺជាការស្រេច។ ប៉ុន្តែដល់ពេលបានមករៀន វាពុំស្រួលដូចយើងគិតទេ ការថតមានរបៀប និងកម្រិតខ្នាតយ៉ាងត្រឹមត្រូវ នេះបើតាមអ្នកជំនាញបានបង្ហាញ។ លោកស៊ិន មករា បានបន្តដែរថា: "ខ្ញុំមានអារម្មណ៍



សប្បាយរីករាយ និងគិតថា ខ្ញុំមានសំណាង ព្រោះយើងមិនមែនបានចូលរៀនដោយងាយៗទេ។

ចំណែកកញ្ញាមាស កណ្ណិកា គឺជានិស្សិតឆ្នាំទីបីផ្នែកតែងលំអ នៅក្នុងសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏ចាប់អារម្មណ៍យ៉ាងខ្លាំងស្រដៀងទៅនឹងមករាផងដែរ លើការថតរូបនេះ។ កញ្ញារៀបរាប់ឱ្យដឹងថា: "ខ្ញុំជាមនុស្សម្នាក់ចូលចិត្តថតរូប។ ប៉ុន្តែនៅពេលខ្ញុំយករូបថត ខ្ញុំខ្លួនឯងដែលមានប្លង់ ដូចគ្នាទៅប្រៀបធៀបជាមួយអ្នកមានវិជ្ជាជីវៈ ខ្ញុំដឹងថា វាមិនស្អាតដូចគេទេ។ ដល់ពេលខ្ញុំបានចូលរៀនទើបខ្ញុំដឹងថា ការថតរូបអ្វីមួយគឺយើងមិនមែនចេះតែថតនោះទេ វាមានតម្រូវការ មានទាំងសោភ័ណនិងអត្ថន័យនៅក្នុងរូបទៀតផង។

April-2010.qxd 6/10/2010 2:56 PM Page 8





Photos : T. Yort

## ខាន់ ភីរម្យ

### កម្ពុជាផ្តល់វ៉ាក់សាំងការពារជំងឺគ្រុនផ្តាសសាយថ្មី

វ៉ាក់សាំងការពារជំងឺគ្រុនផ្តាស-សាយថ្មី AH1N1 បានត្រូវមន្ត្រីក្រសួងសុខាភិបាលផ្តល់ជូនប្រជាពលរដ្ឋដែលងាយរងគ្រោះនៅក្នុងរាជធានីភ្នំពេញ និងខេត្តមួយចំនួនដូចជាកណ្តាល កំពង់ឆ្នាំង និងកំពង់ស្ពឺ ។

វ៉ាក់សាំងដែលប្រឆាំងជំងឺគ្រុនផ្តាសសាយថ្មីនេះ នឹងចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ។

ប្រជាពលរដ្ឋដែលអាចនឹងទទួលវ៉ាក់សាំងថ្មីនេះ គឺរួមមានទារក ដែលមានអាយុចាប់ពី៦ខែ ដល់ ២៤ខែ ស្ត្រីមានផ្ទៃពោះ បុគ្គលិកសុខាភិបាល និងអ្នកជំងឺរលាកសួតរ៉ាំរ៉ៃជាដើម ។

វ៉ាក់សាំងនេះនឹងផ្តល់ជូនពីថ្ងៃទី ២៤ ខែមីនា ដល់ថ្ងៃទី០៤ ខែមេសា ហើយបន្ទាប់មក ការផ្តល់វ៉ាក់សាំងដំណាក់កាលទីពីរនឹងផ្តល់ជូនទូទាំងប្រទេសនៅក្នុងខែឧសភា ដល់ខែមិថុនា ។ វ៉ាក់សាំងនេះ គឺជាអំណោយរបស់អង្គការសុខភាពពិភពលោក ហើយបានប្រកាសជាផ្លូវការដោយឯកឧត្តមម៉ម ប៊ុនហេង ដែលជារដ្ឋ-មន្ត្រីក្រសួងសុខាភិបាល ។

### អាមេរិកយកចិត្តទុកដាក់ពីការរាលដាលជំងឺរបេងនៅកម្ពុជា

កាលពីថ្ងៃទី២៤ ខែមីនា ស្ថានទូតអាមេរិក និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានរៀបចំទិវាជំងឺរបេងពិភពលោកនៅកម្ពុជា ។

លោកស្រីខារ៉ូល រូតលី ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅក្នុងប្រទេសកម្ពុជាបានជំរុញឱ្យរដ្ឋាភិបាល និងអង្គការដៃគូរនានាលើកកម្ពស់ការចូលរួមគ្នាដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺនេះ ។

លោកស្រីបានបញ្ជាក់ថា: "លុះត្រាណាតែយើងទាំងអស់គ្នា ដែលជាដៃគូរធ្វើការងារឱ្យមានប្រសិទ្ធិភាពក្នុងការគ្រប់គ្រងជំងឺរបេង បើមិននោះទេ យើងទាំងអស់គ្នានឹងប្រឈមមុខនឹងគ្រោះថ្នាក់នេះជាមិនខាន" ។

រហូតមកដល់ពេលនេះ អាមេរិកគឺជាម្ចាស់ជំនួយមួយដ៏ធំលើកម្មវិធីកម្ចាត់ជំងឺនេះ ។ តាមរយៈមូលនិធិជាសកល សហរដ្ឋអាមេរិកបានផ្តល់មូលនិធិប្រមាណជា ៤,២លានដុល្លារ ដល់កម្មវិធីកំចាត់ជំងឺរបេងនៅកម្ពុជា កាលពីឆ្នាំ២០០៩ ។

### ខេត្តបាត់ដំបងកំពុងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ៩កន្លែង

គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារា-សាស្ត្រចំនួន ៩កន្លែង នៅក្នុងខេត្តបាត់ដំបង កំពុងតែដំណើរការទៅមុខនៅក្រោមគម្រោងទឹកប្រាក់ចំនួន ៧០លានដុល្លារ ។

មន្ត្រីក្រសួងធនធានទឹក នៅខេត្តបាត់ដំបងបានឱ្យដឹងថា គម្រោងទាំងនេះ មានតម្លៃប្រមាណជា ៧០លានដុល្លារ ក្រោមទឹកប្រាក់កម្ចីពីប្រទេសចិន និងធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងទឹកប្រាក់បដិភាគពីសំណាក់រដ្ឋាភិបាលកម្ពុជា ។

មន្ត្រីរូបនេះបានអះអាងទៀតថា ប្រសិនបើគម្រោងទាំងនេះបានបញ្ចប់នោះ ផ្ទៃដីស្រែចំនួន ៦៥ ភាគរយ ឬស្មើនឹងផ្ទៃដីប្រមាណជា ២៤១,៥០០ ហិចតា នៅក្នុងខេត្តបាត់ដំបង នឹងក្លាយទៅជា ផ្ទៃដីដ៏មានសក្តានុពលសម្រាប់ដំណាំស្រូវ ។

មកដល់ពេលនេះ ខេត្តបាត់ដំបងនៅតែត្រូវបានគេចាត់ទុកថាជាជម្រុកស្រូវមួយដ៏ធំរបស់ប្រទេសកម្ពុជា ។

## លុយដុល្លារឡើងថ្លៃ ចំណែកឯលុយអឺរ៉ូមានតម្លៃធ្លាក់ចុះ




តាមទីភ្នាក់ងារសារព័ត៌មានបារាំង បានអះអាង កាលពីថ្ងៃទី ២៤ មីនា កន្លងទៅនេះថា លុយដុល្លារអាមេរិក បានលោតឡើងយ៉ាងខ្ពស់ធៀបនឹងលុយអឺរ៉ូ ។

ប្រភពដដែលនេះ បានឱ្យដឹងថា នេះគឺជាការឡើងថ្លៃដ៏ខ្ពស់ដំបូងនៅក្នុងរយៈពេល១០ខែកន្លង ទៅនេះដោយលុយអឺរ៉ូ ១អឺរ៉ូនាពេលនេះ មានតម្លៃត្រឹមតែ ១,៣៣ ដុល្លារតែប៉ុណ្ណោះ ។ ក្រៅពីអឺរ៉ូ លុយយ៉េនជប៉ុនក៏បានធ្លាក់ថ្លៃផងដែរ ។ កាលពីសប្តាហ៍មុន លុយដុល្លារ១ដុល្លារ អាចប្តូរបានលុយយ៉េនតែ៩០,៤២ ។ ប៉ុន្តែនៅពេលនេះគឺអាចប្តូរបានរហូតដល់ទៅ ៩២,២៤យ៉េន ។

ប្រភពដដែលនេះ បានឱ្យដឹងថា មូលហេតុនៃការធ្លាក់ចុះនៃអឺរ៉ូនេះដោយសារតែប្រទេសក្រិកជួបនូវបញ្ហា ហើយក្រិកគឺជាសមាជិករបស់សហគមន៍អឺរ៉ុប ។ ដូច្នេះហើយបានជាធ្វើឱ្យតម្លៃលុយអឺរ៉ូ ធ្លាក់ថ្លៃចុះ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏បណ្តាប្រទេសមហាអំណាចនៅអឺរ៉ុបកំពុងតែមានវិធានការដោះស្រាយបញ្ហាទាំងនេះដែរ ។

## អាកាសយានដ្ឋានអន្តរជាតិសិង្ហបុរី ជាប់ចំណាត់ថ្នាក់ស្អាតជាងគេ

អាកាសយានដ្ឋានអន្តរជាតិ ប្រទេសសិង្ហបុរីដែលមានឈ្មោះថា អាកាសយានដ្ឋាន ចាន់ហ្គី បានទទួលជោគជ័យ ជាអាកាសយានដ្ឋានស្អាតជាងគេនៅក្នុងទ្វីបអាស៊ី ។

បើយោងតាមបណ្តាញព័ត៌មាន ធូដេអោនឡាញ បានឱ្យដឹងថា លទ្ធផលពីការអង្កេតមួយដែលធ្វើឡើងដោយអ្នកស្រាវជ្រាវឯកទេសអាកាសយានដ្ឋានដែលជាប់លំដាប់ថ្នាក់ទីមួយនៅអាស៊ី គឺអាកាសយានដ្ឋាន ចាន់ហ្គី ។ អាកាសយានដ្ឋានដែលបានជាប់លំដាប់ទីពី គឺអាកាសយានដ្ឋាន អ៊ីនឆុន នៅក្នុងប្រទេសកូរ៉េខាងត្បូង និងអាកាសយានដ្ឋានហុងកុងជាប់លំដាប់ថ្នាក់លេខបី ។

ជោគជ័យនៃអាកាសយានដ្ឋានចាន់ហ្គីនេះ គឺទទួល ក្រោយពេលដែលអាកាសយានដ្ឋាននេះបានបាត់បង់តំណែងនេះ កាលពីប៉ុន្មានឆ្នាំមុនដោយសារបញ្ហាអនាម័យ ។ ប៉ុន្តែនៅក្រោយពេលអាកាសយានដ្ឋាននេះ បានចាប់ផ្តើមធ្វើនូវយុទ្ធនាការសម្អាតមក អាកាសយានដ្ឋាននេះក៏បានទទួលជោគជ័យឡើងវិញ ។

អាកាសយានដ្ឋាននេះអាចទទួលជើងហោះហើររហូតដល់ ៤,៣០០ជើង នៅក្នុងមួយសប្តាហ៍ ជាមួយនឹងក្រុមហ៊ុនអាកាសចរណ៍ចំនួន៨០ក្រុមហ៊ុន ហើយហោះទៅកាន់ទីក្រុងចំនួន ១៣០ របស់ប្រទេសចំនួន ៥៩ នៅលើពិភពលោក ។

## កិច្ចសម្ភាសន៍

# តើប្រជាពលរដ្ឋអាចប្រើប្រាស់ថាមពលកកើតឡើងវិញ ?

**ខាន់ ភីរម្យ**

*ថាមពលអគ្គិសនីនៅប្រទេសកម្ពុជា មានតិចតួច ហើយភាគច្រើនមាននៅតំបន់ទីប្រជុំជន និងទីក្រុងប៉ុណ្ណោះ។ រីឯនៅតាមជនបទ មានការជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់ថាមពលកកើតឡើងវិញ។ អ្នកនាំសារជួបជាមួយនឹងលោកវិទ្ធ សីហា ប្រធានអង្គការអេសអ៊ឹមអ៊ី វិញ្ញូអេបល អេនើជី ដើម្បីពិភាក្សាលើប្រធានបទនេះ។*


Photo : K. Phirum

លោកវិទ្ធ សីហា ប្រធានអង្គការ អេសអ៊ិមអ៊ី វិញ្ញូអេបល អេនើជី កម្ពុជា

**អ្នកនាំសារ : តើមកដល់ពេលនេះ ប្រជាពលរដ្ឋកម្ពុជាប៉ុន្មានភាគរយ ដែលអាចទទួលនូវថាមពលអគ្គិសនីប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ?**

**លោកវិទ្ធ សីហា** : តាមព័ត៌មាន ដែលខ្ញុំទទួលបាន មកដល់ពេលនេះ ប្រជាពលរដ្ឋខ្មែរ ដែលអាចនឹងកំពុងតែទទួលបានថាមពលអគ្គិសនី ប្រើប្រាស់នោះមានត្រឹមតែពី១៧ ទៅ១៨% ប៉ុណ្ណោះ ហើយភាគច្រើនគឺមានតែនៅតាមទីក្រុង និងតាមទីប្រជុំជនប៉ុណ្ណោះ ។ ចំណែកឯនៅជនបទ គឺសឹងតែគ្មាន ។ ដូច្នេះហើយ ខ្ញុំគិតថាថាមពលកកើតឡើងវិញគឺជាប្រភពថាមពលមួយ ដែលអាចនឹងដោះស្រាយនូវតម្រូវការថាមពលអគ្គិសនីបាន ។

**អ្នកនាំសារ : តើថាមពលដែលកកើតឡើងវិញនេះអាចមានអ្វីខ្លះ ?**

**លោកវិទ្ធ សីហា** : ថាមពលកើតឡើងវិញ ដែលគេអាចប្រើប្រាស់បានក្នុងប្រទេសកម្ពុជា នៅពេលនេះ មានដូចជា ថាមពលដែលទាញចេញពីពន្លឺព្រះអាទិត្យ ថាមពលខ្យល់ ប្រេងជីវម៉ាហ្សូត ប្រេងជីវឥន្ធនៈ ជីវឧស្ម័ន ឧស្ម័នធម្មជាតិ និងជីវម៉ាស ។

**អ្នកនាំសារ : តើថាមពលទាំងនេះគេអាចផលិតចេញមកបានយ៉ាងដូចម្ដេច ?**

**លោកវិទ្ធ សីហា** : ថាមពលពន្លឺព្រះអាទិត្យគឺគេតម្រូវឱ្យមានការប្រើប្រាស់នូវបច្ចេកវិទ្យាខ្ពស់ និងវត្ថុធាតុដើមរាងថ្លៃ ។ សម្រាប់ថាមពលខ្យល់ វិញគឺអាចដែរ ។ ប៉ុន្តែជាប្រក្រតី វាអាចដើរបានដោយសារតែកង្ហារមួយ ដែលអាចវិលជាមួយនឹងថាម-ពលខ្យល់ជាមធ្យម ៥គីឡូម៉ែត្រក្នុងមួយវិនាទី តែនៅកម្ពុជាល្បឿនខ្យល់គឺយឺតបន្តិច គឺវាមានកម្លាំងត្រឹមតែ ៣គីឡូម៉ែត្រប៉ុណ្ណោះ នៅក្នុងមួយវិនាទី ។ សម្រាប់ប្រេងជីវម៉ាហ្សូតវិញ គេក៏កំពុងតែផលិតចេញពីល្ហុងខ្វង ។ រីឯប្រេងជីវឥន្ធនៈវិញ គឺគេផលិតពីពោត ដំឡូងមីជាដើម ហើយនៅកម្ពុជាពេលនេះមានរោងចក្រមួយ កំពុងតែដំណើរការ ។ សម្រាប់ជីវម៉ាស់វិញ គឺជាគម្រោងដែលកំពុងតែដំណើរការដោយអង្គការខ្ញុំផ្ទាល់ វាអាចនឹងផ្ដល់ ថាមពលបានបង្គួរ ហើយអាចមានតម្លៃថោកជាមួយនឹងការដុតអង្កាម និងស្នូលពោត ជាដើម ។ រីឯឧស្ម័នធម្មជាតិវិញ មានដូចជាលាមកសត្វ និងកម្ទេចកម្ទីផ្ទះបាយជាដើម ។ សម្រាប់ថាមពលជីវម៉ាស់វិញ នៅកម្ពុជានាពេលបច្ចុប្បន្ននេះ វាជាគម្រោងមួយដែលកំពុងតែដំណើរការដែរ តែភាគច្រើន គឺជាគម្រោងតាមបែបជាលក្ខណៈគ្រួសារ ។

**អ្នកនាំសារ : តើបញ្ហាដែលប្រឈមមុខ និងរាំងស្ទះទៅដល់ការប្រើប្រាស់ថាមពលកកើតឡើងវិញសម្រាប់ប្រជាពលរដ្ឋ ?**

**លោកវិទ្ធ សីហា** : មកដល់ពេលនេះដែរ បញ្ហាប្រឈមយ៉ាងខ្លាំងរាំងស្ទះក្នុងការជំរុញឱ្យប្រជា-ពលរដ្ឋប្រើប្រាស់ថាមពលកកើតឡើងវិញនោះ គឺបញ្ហាតម្លៃដែលភាគច្រើន គឺការចំណាយសម្រាប់ផលិតឡើងវិញនេះត្រូវការថ្លៃដើមថ្លៃ ហើយកង្វះខាតការយល់ដឹងអំពីបញ្ហាបរិស្ថានក៏ជាបញ្ហាដែរ ។


Photo : DR

ម៉ាស៊ីនផលិតឥន្ធនៈជីវម៉ាសក្រោមការត្រួតពិនិត្យពីអ្នកគ្រប់គ្រង និងអ្នកឯកទេសជំនាញ។ នេះគឺជាម៉ាស៊ីនផលិតថាមពលដែលសក្ដិសមបំផុតនៅជនបទ ពីព្រោះវាស្ថិតក្នុងតំបន់នៃវត្ថុធាតុដើមផ្ទាល់។

### បញ្ហាថាមពលកកើតឡើងវិញ

លោក វិទ្ធ សីហា ប្រធានអង្គការ អេសអ៊ិមអ៊ី វិញ្ញូអេបល អេនើជី បានឱ្យដឹងថា តម្លៃគឺជាឧបសគ្គចម្បងដោយសារតែសម្ភារៈនៅក្នុងការទាញយកថាមពលអគ្គិសនីកកើតឡើងវិញនេះ គឺវាថ្លៃបន្តិច ហើយអាចផលិតថាមពលបានតិច។ ជាក់ស្ដែងបើគាត់ចង់ប្រើប្រាស់ថាមពលឧស្ម័នធម្មជាតិជាលក្ខណៈគ្រួសារ គឺគាត់អាចទទួលបានត្រឹមភ្លើងចម្អិន និងបំភ្លឺតិចតួច។ តែបើគាត់ចង់បានភ្លើងប្រើប្រាស់គ្រប់គ្រាន់ គឺត្រូវវិនិយោគធ្វើរោងចក្រជីវម៉ាស់ ដោយដុតអង្កាម ឬវត្ថុសរីរាង្គផ្សេងៗ។ តួយ៉ាងគាត់ត្រូវការដើមទុនរហូតដល់ទៅ ៦៥០០០ ដុល្លារឯណោះ ដើម្បីកសាងបានរោងចក្រមួយសម្រាប់សហគមន៍ជាមួយនឹងថាមពលចំនួន ២០០គីឡូវ៉ាត់។

April-2010.qxd 6/10/2010 2:56 PM Page 10

## បទយកការណ៍

# តែងតាំងលោកអភិបាលឧបត្ថម្ភព្រះសហគមន៍កាតូលិកភ្ន

**ខាន់ ភីរម្យ**



Photo : L.Sovanna

គ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិករាប់ពាន់នាក់ មកពីព្រះសហគមន៍កាតូលិកទាំងបីភូមិភាគនៅក្នុងប្រទេសកម្ពុជា ហើយនិងតំណាងសាសនានានាបានចូលរួម និងស្វាគមន៍លោកអូលីវីយេ ជ្មិត-ហាស្លេរ ដែលទទួលអគ្គសញ្ញាតែងតាំងជាអភិបាលឧបត្ថម្ភក នៃព្រះសហគមន៍ភូមិភាគភ្នំពេញកាលពីថ្ងៃសៅរ៍ ទី២០ មីនា ឆ្នាំ២០១០ កន្លងទៅថ្មីៗ នេះនៅ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដុនបូស្កូ សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ ។

គណៈកម្មាធិការរៀបចំធ្វើពិធីតែងតាំងលោកអភិបាល បានឱ្យដឹងថា ពិធីតែងតាំងនេះបានទទួលការចូលរួមពីសំណាក់សមាជិកព្រះសហគមន៍ទាំងបីភូមិភាគចំនួនលើសពី ៥៥០០នាក់ ព្រមទាំងមានការអបអរពីសម្តេចសង្ឃទាំងពីរគណៈនៅប្រទេសកម្ពុជា តំណាងក្រសួងធម្មការ និងកិច្ចការសាសនាអាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាលកាតូលិក ។

លោកយេង បេ អាយុ៧២ឆ្នាំ គ្រីស្តបរិស័ទ មកពីព្រះសហគមន៍កាតូលិកអ្នកលឿង បានឱ្យដឹងថាៈ "២០ មីនា ឆ្នាំ២០១០ គឺជាថ្ងៃប្រវត្តិសាស្ត្រនៃព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា" ។

អ្នកស្រីទុត លាប អាយុ ៥៦ឆ្នាំ ជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍នៅស្រុកបាវិល ខេត្តបាត់ដំបងបានមានប្រសាសន៍ដែរថា : "នេះគឺជាលើកទីមួយហើយនៅក្នុងជីវិតរបស់ខ្ញុំ ដែលបានឃើញទិដ្ឋភាពពិតប្រាកដនៃពិធីតាមបែបកាតូលិក" ។អ្នកស្រីបានបញ្ជាក់ទៀតថា : "តាំងពីក្មេង រហូតដល់ពេលនេះខ្ញុំអាចឃើញតែពិធីបែបពុទ្ធសាសនា ដូចជា បុណ្យផ្កាមាឃបូជា បញ្ចុះសីមា ដែលវាជាពិធីបែបពុទ្ធ-សាសនា និងពិធីថ្វាយអភិបូជា នៅតាមសហគមន៍កាតូលិកតូចៗតែប៉ុណ្ណោះ ។ ប៉ុន្តែថ្ងៃនេះ ខ្ញុំមានការរំភើបណាស់ដែលបានឃើញពិធីថ្វាយអភិបូជាដ៏ធំហើយមានមនុស្សរាប់ពាន់នាក់ ចូលរួម ជាពិសេសគឺបានឃើញ ទិដ្ឋភាពប្លែកៗ និងបូជាចារ្យជាច្រើនដែលចូលរួម" ។

លោកមុត សារី អាយុ៥២ឆ្នាំ មកពីព្រះសហ-គមន៍ល្វាឯម ខេត្តកណ្តាល ក៏បានមានប្រសាសន៍ថានេះគឺជាថ្ងៃប្រវត្តិសាស្ត្រនៃព្រះសហគមន៍ភូមិភាគភ្នំពេញលើកទី២ហើយ ដែលខ្ញុំបានឃើញ ។ លោកបានបញ្ជាក់ថាៈ "មួយជីវិតខ្ញុំនេះ ខ្ញុំមានឱកាសចូលរួមពិធីតែងតាំងលោកអភិបាល ប្រចាំព្រះសហគ-មន៍ភូមិភាគភ្នំពេញពីរដងដែរ" ។ តាមការរៀបរាប់របស់លោកមុត សារី កាលពីឆ្នាំ១៩៩៧ គាត់ក៏បានចូលរួមក្នុងពិធីតែងតាំងលោកអភិបាលអេមីលដេតម្បូម្តងហើយ ។

ក្រៅពីគ្រីស្តបរិស័ទបព្វជិត-បព្វជិតាអស់លោកបូជាចារ្យទាំងអស់ដែលបានចូលរួម ក៏បានបង្ហាញក្តីសង្ឃឹមអំពីការរីកចម្រើនរបស់ព្រះសហគមន៍ នៅក្នុងពេលអនាគតផងដែរ ។

លោកសុខ ណា អាយុ៣០ឆ្នាំ គឺជានិស្សិតទេវ-វិទ្យាល័យមកពីព្រះសហគមន៍ចំប៉ា ក៏បានឱ្យដឹងថាគាត់មានអារម្មណ៍សប្បាយណាស់ និងអរព្រះគុណព្រះជាម្ចាស់ ដែលបានបណ្តាលចិត្ត ឱ្យសម្តេចប៉ាបបេណេឌីកទី១៦ ជ្រើសរើសលោកអូលីវីយេជាអ-ភិបាលរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញ ។

## ប្រវត្តិព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

**ព្រះសហគមន៍ភូមិភាគភ្នំពេញបានចាប់កំណើតឡើងជាង៥០ឆ្នាំកន្លងមកហើយ។ ព្រះមហាក្សត្រខ្មែរសម្តេចព្រះបាទនរោត្តម បានស្នើសុំឱ្យព្រះសហគមន៍នៅពញាឮ រើមកកាន់ទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៨៦៦។ ព្រះសហគមន៍ភូមិភាគភ្នំពេញបានបន្តរីកចម្រើនជាលំដាប់រហូតដល់សម័យខ្មែរក្រហម ក៏ត្រូវរងនូវការបំផ្លិចបំផ្លាញដូចជាសាសនាដទៃទៀតដែរ។**

**ក្រោយរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ព្រះសហគមន៍បានចាប់កំណើតឡើងវិញ។ ប៉ុន្តែសេរីភាពនៃជំនឿនៅមិនទាន់ទទួលការបើកចំហទេរហូតដល់ឆ្នាំ១៩៩០។ លោកអូលីវីយេជាអភិបាលនៃព្រះសហគមន៍ទីបី បន្ទាប់ពីព្រះសហគមន៍រស់ឡើងវិញក្រោយរបបខ្មែរក្រហម។ លោកអភិបាលទី១ គឺលោកអ៊ីវ រ៉ាម៉ូស និងទីពីរគឺលោកអេមីល ដេតម្បូ។ ភូមិភាគភ្នំពេញមានគ្រីស្តបរិស័ទ ១៣០០០នាក់ និង៣៨ព្រះវិហារ។**

April-2010.qxd 6/10/2010 2:56 PM Page 11

# តូលិកភូមិភាគភ្នំពេញ



លោកក៏បញ្ជាក់ថា : "លោកអូលីវីយេជាបូជាចារ្យដ៏មានប្រជាប្រិយភាពម្នាក់ក្នុងចំណោមបូជាចារ្យមានប្រជាប្រិយភាពនានានៅក្នុងព្រះសហគមន៍។ ខ្ញុំរំភើបហើយសង្ឃឹមថា បេសកកម្មរបស់ព្រះសហគមន៍នឹងរីកចម្រើនទៅមុខ ដោយសារតែអភិបាលបូជាចារ្យ បងប្រុស បងស្រី និងសមាជិកព្រះសហគមន៍ទាំងអស់ ធ្វើការក្រោមបេសកកម្ម និងជំនឿតែមួយ។ ខ្ញុំបានត្រៀមខ្លួនរួចរាល់ហើយនៅក្នុងការចូលរួមក្នុងនាមជាសហការីរបស់លោកអភិបាលថ្មីរបស់យើង ប្រកបដោយការគោរព និងអំណរសប្បាយ"។

បងស្រីច្រឹក ស៊ីណា សមាជិកក្រុមគ្រួសារឧបការគុណ បាននិយាយថា បងស្រីសូមចូលរួមអំណរសប្បាយចំពោះពិធីតែងតាំងលោកអភិបាលថ្មីៗនៃព្រះសហគមន៍ភូមិភាគភ្នំពេញផងដែរ។ បងស្រីក៏បានមានប្រសាសន៍ដែរថា: "ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលផ្តល់ឱ្យយើងនូវអភិបាលថ្មី សម្រាប់ភូមិភាគភ្នំពេញ។ ខ្ញុំគិតថា ផ្នែកអប់រំសង្គម ព្រមទាំងកិច្ចការអប់រំជំនឿ នឹងត្រូវផ្លាស់ប្តូរ ហើយវិវត្តច្រើននៅពេលអនាគត។ ខ្ញុំគិតថា នេះគឺជាពេលដ៏ល្អសម្រាប់យើង និងលោកអភិបាលថ្មីរួមគ្នា ធ្វើឱ្យព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជារបស់យើងរីកចម្រើនទៅមុខ"។ បងស្រីបាន មានប្រសាសន៍បន្តទៀតថាផ្អែកទៅតាមបទពិសោធន៍នៃការប្រកាសដំណឹងល្អ។ យើងដឹងថា វាគឺមានបញ្ហាប្រឈម ជាច្រើន នៅពេលដែលយើង និយាយទៅកាន់មនុស្សមកពីសាសនាផ្សេងៗជាក់ស្តែង យើងត្រូវតែដឹងពីវប្បធម៌ ប្រពៃណី និងទម្លាប់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋ នៅមូលដ្ឋាននោះ។ ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាភាគច្រើន គឺជាអ្នកកាន់សាសនាព្រះពុទ្ធ។ ដូច្នេះនៅក្នុងនាមយើងជាព្រះសហគមន៍យើងត្រូវនិយាយជាមួយនឹងពួកគាត់តាមរយៈការជួយប្រជាជនងាយរងគ្រោះ ការអប់រំ និងធ្វើកិច្ចការមនុស្សធម៌ជាមួយយុវជនជាដើម។

ក្រៅពីបងស្រីខាងលើ លោកស៊្រុំប្រាម៉ុងវីរជ័យ បូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍មណ្ឌលសកម្មភាពព្រះសីហនុ បានមានប្រសាសន៍ថា វត្តមាននៃអភិបាលថ្មី នឹងនាំមកនូវការរីកចម្រើនថ្មីៗនៅក្នុង ព្រះសហគមន៍កាតូលិក និងនៅក្នុងសង្គមប្រទេសកម្ពុជា។ លោកបូជាចារ្យបានបញ្ជាក់ថា : "ព្រះគម្ពីរបានចែងថា អ្នកដែលមកក្រោយខ្ញុំ មានកម្លាំងខ្លាំងជាងខ្ញុំ។ អភិបាលថ្មីគឺក្មេងមានជំនឿមាំមួន ហើយមានគំនិតដើម្បីជួយ និងអភិវឌ្ឍព្រះសហគមន៍យើងច្រើន"។

លោកបានបន្តទៀតដែរថា: "នៅពេលណាដែលយើងមានអ្វីមួយថ្មីនោះ មានន័យថាព្រះសហគមន៍ក៏នឹងរីកចម្រើនថ្មីដែរ។លោកអភិបាលថ្មីរបស់យើងនឹងមានទស្សនៈថ្មីៗ ដើម្បីអភិវឌ្ឍព្រះសហគមន៍ ហើយនេះក៏ជាអ្វីដែលលោកអភិបាលចាស់របស់យើង គឺលោកអេមីល ដេតម្ប សង្ឃឹមនៅក្នុងពេលចុងក្រោយរបស់គាត់"។

លោកអូលីវីយេ ត្រូវបានតែងតាំង ជាអភិបាលឧបត្ថម្ភកនៃភូមិភាគភ្នំពេញនៅក្នុងប្រទេសកម្ពុជា ដោយសម្តេចប៉ាបបេណេឌីកទី១៦ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ កន្លងទៅនេះ។

លោកអូលីវីយេកើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧០ នៅស្ត្រាសប៊ួ ប្រទេសបារាំង។ លោកបានទទួលអគ្គសញ្ញា ជាបូជាចារ្យ នៅក្នុងឆ្នាំ១៩៩៨។ ហើយនៅក្នុងឆ្នាំដដែលនោះ លោកបានធ្វើដំណើរមកជួយព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជារហូតដល់ពេលបច្ចុប្បន្ននេះ។ ក្នុងបេសកកម្មមនុស្សធម៌ និងជាសាសនទូតមួយរូប លោកបានបម្រើ និងជួយដល់ព្រះសហគមន៍ និងប្រជាជនក្រីក្រជាច្រើន។

សមិទ្ធផលមនុស្សធម៌ ដែលលោកបានធ្វើ គឺរួមមានសាលារៀន បឋមសិក្សា មធ្យមសិក្សា វិទ្យាល័យ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងវិទ្យាស្ថានបណ្តុះបណ្តាលជាន់ខ្ពស់មួយ នៅឯស្រុកត្រាំកក់ខេត្តតាកែវ។

លោកអូលីវីយេ បានមានប្រសាសន៍នៅក្រោយពេលបញ្ចប់ នូវពិធីតែងតាំងថា លោកមានសេចក្តីរំភើប និងអរគុណដល់ព្រះជាម្ចាស់ សម្រាប់តួនាទីថ្មីជាអភិបាលមួយរូប ក្នុងប្រទេសកម្ពុជា។ លោកបានបញ្ជាក់ថា : "ព្រះសហគមន៍ជាអ្នកត្រាស់ហៅខ្ញុំឱ្យក្លាយជាអ្នកបន្តវេននៅភូមិភាគ ក្នុងតួនាទី ជាអភិបាល ហើយនេះជាអំណោយទានពីព្រះវិញ្ញាណដ៏វិសុទ្ធ។ សេចក្តីស្រលាញ់របស់ព្រះគ្រីស្តបានជំរុញយើង។ គេសួរខ្ញុំថា ឃ្លានេះមានន័យយ៉ាងម៉េច? ខ្ញុំអាចប្រាប់អ្នកបានថា អាទិភាពដ៏ចម្បង របស់ព្រះសហគមន៍គឺការអប់រំ គឺជា"ការអប់រំគណៈកម្មការនីមួយៗនៅក្នុងព្រះសហគមន៍ គឺតម្រូវការឱ្យមានទំនួលខុសត្រូវច្បាស់លាស់ និងជាសាក្សីនៃសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ព្រះបេះដូងរបស់ព្រះយេស៊ូធ្វើឱ្យយើងបង្ហាញនូវយុត្តិធម៌ សន្តិភាព ព្រមទាំងចិត្តមេត្តាករុណាផងដែរ"។

## អភិបាលភូមិភាគភ្នំពេញនៅក្នុងសម័យអន្តកាល

ព្រះសហគមន៍ភូមិភាគភ្នំពេញបានចាប់កំណើតឡើងជាង៤៥០ឆ្នាំ និងបានរីកចម្រើនរហូតដល់សម័យអន្តកាលបីឆ្នាំនៃរបបខ្មែរក្រហម។ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញមួយរូបបានបាត់បង់ជីវិត នោះគឺលោកយ៉ូសែប ឆ្មារសាឡាស់។ លោកបានបាត់បង់ជីវិតនៅក្នុងឆ្នាំ១៩៧៧ ក្រោយពេលដែលលោកបានត្រូវតែងតាំង ជាអភិបាលនៃព្រះសហគមន៍នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។

លោកគឺជាអភិបាលខ្មែរទីមួយដែលទទួលអគ្គសញ្ញាជាអភិបាលនៃព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា។ លោកបានបាត់បង់ជីវិតដោយធ្វើការបាក់កម្លាំងនៅក្នុងវត្តថ្លាស្រុកបារាយខេត្តកំពង់ធំ ហើយបច្ចុប្បន្នទីកន្លែងដែលលោកបានបាត់បង់ជីវិតនោះត្រូវបានសមាជិកព្រះសហគមន៍ចាត់ទុកថាជាទឹកដីមរណសាក្សីរបស់ព្រះសហគមន៍ដែលសម្តេចប៉ាបយ៉ូហានប៉ូល ទី២ ចាត់ថ្ងៃទី៧ ខែឧសភា គឺជាថ្ងៃរំឭកមរណសាក្សីនៅកម្ពុជា។

April-2010.qxd 6/10/2010 2:56 PM Page 12



# ជំនួបស្តីអំពីសមធម៌យេនឌ័របុរសស្ត្រី ក្នុងសហគមន៍ឃុំរលួស

**តន**



Photo : Torn

អង្គការការីតាសកម្ពុជា ធ្វើសហការជាមួយនិង អាជ្ញាធរស្រុកកណ្តាលស្ទឹងរៀបចំអង្គសិក្ខាសាលាស្តីអំពី "ការលើកកម្ពស់សក្តានុពលរបស់ស្ត្រី និង យុវជនក្នុងការអភិវឌ្ឍសង្គមជាតិ"។

អង្គសិក្ខាសាលានេះរៀបចំឡើងនៅក្នុងវត្តព្រះធាតុ ដែលស្ថិតក្នុងភូមិក្រពើទ្រោម ឃុំរលួស ស្រុកកណ្តាលស្ទឹង នាខេត្តកណ្តាល ដែលមានអ្នកចូលរួម ៣០៩នាក់ដែលជាងពាក់កណ្តាលគឺស្ត្រី។ អង្គសិក្ខាសាលានេះធ្វើនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០។

ចំពោះការបើកអង្គប្រជុំ លោកស្រីទេសសុភាព តំណាងឱ្យអាជ្ញាធរស្រុកកណ្តាលស្ទឹង បានថ្លែងថា: "គោលដៅរបស់យើង គឺចង់ធ្វើការបញ្ជ្រាបសមធម៌យេនឌ័រ រវាងបុរស និងស្ត្រី ក្នុងការកាត់បន្ថយ និងលុបបំបាត់ចោលនូវអំពើហិង្សាក្នុងគ្រួសារ។"

កញ្ញាទិក សុភ័ក្រ្ត ជាអ្នកសម្របសម្រួលកម្មវិធីសមធម៌យេនឌ័រ និងប្រឆាំងអំពើជួញដូរមនុស្សនៃ អង្គការ ការីតាសកម្ពុជា បាននិយាយថា ស្ត្រីដែលរស់នៅតាមសហគមន៍មិនមានការយល់ដឹងពីបញ្ហាសិទ្ធិរបស់ខ្លួន។ ហេតុនេះតាមរយៈសិក្ខាសាលាពួកគាត់នឹងមាននូវការយល់ដឹង អំពីសិទ្ធិ និងសមធម៌យេនឌ័រនៅក្នុងគ្រួសារ ក៏ដូចជា នៅក្នុងសហគមន៍ផងដែរ។ កញ្ញាបន្តទៀតថា នេះជាលើកទី១ហើយ ដែលអង្គការការីតាសកម្ពុជា បានសហការ ជាមួយនឹងអាជ្ញាធរដែនដីរៀបចំកម្មវិធីនេះឡើង។

លោកស្រីចាប ពេជ្រ វ័យ៤៧ឆ្នាំ ជាកសិករភូមិក្រពើទ្រោម បាននិយាយថា កាលពី៣ឆ្នាំមុន អ្នកស្រី និង កូន៦នាក់ រស់នៅដោយភាពភ័យខ្លាច និងការវាយដំពីសំណាក់ប្តី និងឪពុកប្រមឹក។ លោកប្តីរបស់គាត់មិនរវីរវល់នឹងរកចំណូលចូលក្នុងគ្រួសារឡើយ ពីព្រោះរូបគាត់មានផ្ទុកនូវមេរោគអេដស៍។ ហេតុនេះនៅរាល់សព្វកិច្ចការ អ្នកស្រីក៏ត្រូវទទួលរ៉ាប់រង។ ទោះជាយ៉ាងណាក្តី អ្នកស្រីអះអាងថា : "មកដល់ឥឡូវ ខ្ញុំពិតជាអរគុណខ្លាំងណាស់ ចំពោះអង្គការការីតាសដែលជួយក្រុមគ្រួសារខ្ញុំឱ្យមានមុខរបរ ជាអ្នកលក់បន្លែក្នុងភូមិ។ ហើយប្តីរបស់ខ្ញុំក៏មិនបានវាយតប់ខ្ញុំ និងកូន ដូចមុនទៀតឡើយ។ មួយឆ្នាំនេះ គ្រួសារខ្ញុំមានតែសុភមង្គល"។

ចំណែកលោកចាប រស់សេចក្តី អ្នកទទួលបន្ទុកផ្នែកអភិវឌ្ឍន៍សហគមន៍នៃអង្គការការីតាស បាននិយាយថា ដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ អង្គការការីតាសកម្ពុជា អនុវត្តបន្ថែមលើទិសដៅ ៤ជំហាន ក្នុងសហគមន៍ដូចជា ការបង្កើតនូវទីផ្សារសហគមន៍ ការបង្កើតនូវក្រុមផលិត ក្រុមអភិវឌ្ឍន៍ ក្រុមផ្សព្វផ្សាយសហគមន៍ និងការបង្កើតនូវក្រឡាបញ្ជីសហគមន៍ ដែលមានការសហការជាមួយនឹងធនាគារអេស៊ីលីដាជាដើម។

## ការីតាសប្រគល់សញ្ញាបត្រដល់សិស្ស ជំនាន់ទី១៨ នៃកម្មវិធីអភិវឌ្ឍន៍យុវជន

យុវជនចំនួន១២៣នាក់ បានអង្គុយជាជួរនៅមុខវេទិកា ដែលមានសរសេរថា: "អបអរសាទរពិធីប្រគល់សញ្ញាបត្រ" ដែលបានប្រព្រឹត្តិទៅនៅភូមិតាក្តុល ឃុំតាក្តុល ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែមីនាកន្លងទៅ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម ប៉ុក ប៉ាន អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោកស្រីហែម សម្បត្តិអភិបាលរងក្រុងតាខ្មៅ និងលោកអភិបាលគីកេ នាយកនៃអង្គការការីតាសកម្ពុជា ព្រមទាំងភ្ញៀវកិត្តិយស ជាច្រើនរូបទៀតផងដែរ។

កញ្ញាសារី ភីរម្យ អ្នកសម្របសម្រួលកម្មវិធីអភិវឌ្ឍន៍យុវជន ក៏បាននិយាយក្នុងឱកាសនេះថា ទាំងនេះជាសមិទ្ធផលដែលប្អូនៗយុវជនបានខិតខំសិក្សាឱ្យមានជំនាញ យ៉ាងពិតប្រាកដមួយ ដើម្បីប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន ក៏ដូចជាការលើកកម្ពស់សេដ្ឋកិច្ចជាតិផងដែរ។

ថ្លែងនៅក្នុងអង្គពិធីឯកឧត្តមប៉ុក ប៉ាន់ ក៏មានប្រសាសន៍ថា នេះគឺជាភាពជោគជ័យរបស់ប្អូនៗ ដែលបានបញ្ចប់នូវការសិក្សាខ្លួនដើម្បីបន្តភារកិច្ចក្នុងការអភិវឌ្ឍសង្គមជាតិ។ យ៉ាងណាមិញ ការបណ្តុះបណ្តាលក្រុមយុវជនជាគោលដៅអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិរបស់ការីតាស ក៏ដូចជាទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកិច្ចការបណ្តុះបណ្តាលធនធានមនុស្ស។ ហេតុនេះ ខ្ញុំសូមបន្តគាំទ្រសកម្មភាពរបស់ការីតាសទៅមុខ។

លោកអភិបាលគីកេ ហ្វីហ្គារេដូ ប្រធានអង្គការការីតាសកម្ពុជា ថ្លែងក្នុងការបិទអង្គពិធីថា : "ពិតមែន! នេះគឺជាផ្លូវមួយដែលយើងគួរតែបើកចំហសម្រាប់យុវជនដើម្បីបង្ហាញ និងបញ្ចេញនូវសមត្ថភាពលើការអភិវឌ្ឍខ្លួនឯង និងសង្គមជាតិ ហើយយើងគួរតែបន្តជំរុញលើកទឹកចិត្តរបស់គេឱ្យស្រលាញ់ការសិក្សាផងដែរ"។ **តន**

April-2010.qxd 6/10/2010 2:56 PM Page 13



# បង្កើនសមត្ថភាពស្តាប់ដើម្បីកាត់បន្ថយទំនាស់

"ការស្តាប់ និងប្រភព អាចបង្កឱ្យមានទំនាស់" ត្រូវបានលើកយកមកពិភាក្សានៅក្នុងសិក្ខាសាលារយៈពេលពីរថ្ងៃ សម្រាប់យុវជននៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដែលបានធ្វើឡើងនៅព្រះសហគមន៍កាតូលិក អ្នកលឿង។ សិក្ខាសាលាមានការចូលរួមពីតំណាងយុវជនយុវនារី ២៨នាក់ មកពីព្រះសហគមន៍ចំនួន៦ កាលពីថ្ងៃទី៣ មីនា។

លោកបូជាចារ្យ អ៊ីវ៉ាន់ កំប៉ាញ៉ា អ្នកទទួលខុសត្រូវយុវជនក្នុងភូមិភាគកំពង់ចាម មានប្រសាសន៍ថា : "សិក្ខាសាលានេះគឺចង់ឱ្យសិក្ខាកាមបានយល់ឥទ្ធិពលនៃការស្តាប់ ដែលវាអាចជួយកសាងទំនាក់ទំនងល្អនិងអាចជួយបង្ការទំនាស់ផងដែរ"។

លោកបូជាចារ្យឡាយ ប៉ូល អ្នកទទួលបន្ទុកក្នុងព្រះសហគមន៍អ្នកលឿង បានមានប្រសាសន៍ថា : "ភាពខ្សោយគឺការដែលយើងមិនចេះស្តាប់គ្នាដែលធ្វើឱ្យរឿងតូចក្លាយទៅជារឿងធំ។ ដូច្នេះបើយើងមានបញ្ហា យើងគួរយកបញ្ហាមកពិភាក្សាគ្នា នោះវានឹងធ្វើឱ្យយើងរីកចម្រើន។

លោកអែម សឿម ជាគ្រូទេសនាមបានពន្យល់ដល់សិក្ខាកាមថា: "ការស្តាប់គឺជាសមត្ថភាពក្នុងការទំនាក់ទំនង។ អ្នកស្តាប់ល្អគឺជាអ្នកដែលផ្តល់ឱកាសដល់អ្នកមានបញ្ហានិយាយអំពីរឿងរបស់គេ"។

កញ្ញាឡេង ថាវី បានរៀបរាប់ថា: "ការស្តាប់ជាគំនិតមួយល្អ ពីព្រោះយើងនឹងក្លាយជាអ្នកស្តាប់ល្អទៅថ្ងៃក្រោយ ព្រោះពេលខ្លះនៅពេលយើងស្តាប់មានចំនុចខ្លះត្រឹមត្រូវដែលធ្វើឱ្យយើងអាចធ្វើការពិចារណា ដើម្បីជៀសវាងការប្រព្រឹត្តខុសឆ្គង។

**ហ៊ួ សុខធារី**


Photo : H.Soktheary

លោកបូជាចារ្យ អ៊ីវ៉ាន់ កំប៉ាញ៉ា (រូបកណ្តាល) រួមជាមួយយុវជនយុវនារីជាសិក្ខាកាមទាំងអស់កាលពីថ្ងៃទី១៥ មីនាកន្លងទៅ នៅព្រះសហគមន៍អ្នកលឿង

## ពិធីសច្ចាប្រណិធានលើកដំបូងរបស់ ម៉ារី ម៉ាដាឡា គឹក សុខលីន

ក្រុមគ្រួសារបងស្រី អ្នកបម្រើបេះដូងព្រះនាងម៉ារី (SIHM) ខេត្តកំពង់ធំ ភូមិភាគបាត់ដំបងមានកិត្តិយសសូមគោរពអញ្ជើញចូលរួមអំណរសប្បាយនាពិធីអរព្រះគុណចំពោះព្រះជាម្ចាស់ក្នុងពិធីសច្ចាប្រណិធានជាលើកដំបូងរបស់ម៉ារី ម៉ាដាឡា គឹក សុខលីន។ មានអភិបូជាក្រោមអធិបតីភាពរបស់លោកអភិបាលហ្វីការេដូ អេនរីកេ (SJ) អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបងនៅថ្ងៃព្រហស្បតិ៍ ទី៦ ខែឧសភា ឆ្នាំ២០១០ នាវេលាម៉ោង ១០ព្រឹក នៅព្រះវិហារគង្វាលដ៏សប្បុរស នាភូមិកំពង់រទេះ ខេត្តកំពង់ធំ ភូមិភាគបាត់ដំបង។

ថ្ងៃពុធទី ០៥ ឧសភា ២០១០ វេលាម៉ោង ១៨:៣០ ល្ងាច មានការអធិដ្ឋាន សម្រាប់ការត្រាស់ហៅ នៅកំពង់រទេះ។ ក្រោយអភិបូជាសូមគោរពអញ្ជើញដល់ភ្ញៀវកិត្តិយសចូលរួមពិសារភោជនាហារដោយរីករាយ។

ដើម្បីសម្រួលការរៀបចំកម្មវិធីនេះ ភ្ញៀវដែលចង់ចូលរួម សូមទូរស័ព្ទមកលេខ: **០១២ ៦៧៣ ៥៨៣** ឱ្យបានមុនថ្ងៃពុធ ទី០៥ ខែឧសភា ឆ្នាំ២០១០។ **សូមអរគុណ!**

# ម៉ារីណុលបណ្តុះបណ្តាលបុគ្គលិកអំពីការអប់រំកុមារ

**ជុង យ៉ត**

អង្គការម៉ារីណុលនៅកម្ពុជា បានរៀបចំសិក្ខាសាលាមួយស្តីពីការអប់រំវិន័យជាវិជ្ជមាន សម្រាប់អនាគតកុមារនៅក្នុងប្រទេសកម្ពុជា កាលពីថ្ងៃទី៩ ដល់ថ្ងៃទី១២ ខែមីនាកន្លងទៅ នៅឯសាលប្រជុំនៃការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកនាទីក្រុងភ្នំពេញ។ កម្មវិធីនេះក៏មានការចូលរួមអំពីសំណាក់លោកបូជាចារ្យ បងស្រី និងបុគ្គលិកពីគ្រប់គម្រោងទាំងអស់របស់អង្គការម៉ារីណុលនៅប្រទេសកម្ពុជាប្រមាណ ជាង៨០នាក់។

បងស្រីអាដែល អារីខែន ទីប្រឹក្សាផ្នែកកិច្ចការសង្គម និងជំងឺអេដស៍ និងជាសាសនទូតម៉ារីណុលក៏បានមានប្រសាសន៍ថា យើងបង្កើតឱ្យមានសិក្ខាសាលានេះឡើង គឺដើម្បីអប់រំបុគ្គលិកអង្គការម៉ារីណុលទាំងអស់ ដែលកំពុងធ្វើការគ្រប់គម្រោងជាមួយក្មេងៗ ឱ្យគេយល់ដឹងអំពីរបៀបអប់រំក្មេង ជាវិជ្ជមានដោយសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ និងជាពិសេសគឺជៀសឱ្យផុតអំពីការប្រើអំពើហិង្សា លើកុមារទាំងផ្លូវកាយ និងផ្លូវចិត្តក្នុងពេលក្រុមបុគ្គលិកការងារចុះទៅធ្វើការបង្រៀន និងចុះអប់រំតាមសហគមន៍។


Photo : Mary

បុគ្គលិកអង្គការម៉ារីណុលដែលចូលរួមក្នុងសិក្ខាសាលា

បងស្រីបានបន្តថា វិន័យជាវិជ្ជមានគឺសំដៅទៅលើរបៀបដោះស្រាយនូវបញ្ហា ដោយផ្អែក នៅលើគោលការណ៍ជាមូលដ្ឋានក្នុងការគោរពសិទ្ធិកុមារ និងការអភិវឌ្ឍ។ ហើយក្នុងនោះឪពុកម្តាយ ឬអាណាព្យាបាល មានតួនាទីសំខាន់ណាស់ក្នុងការអប់រំបីបាច់ និងគាំទ្រកូនរបស់ពួកគាត់ទាំងផ្លូវកាយ និងផ្លូវចិត្ត។ ម្យ៉ាងវិញទៀតការអប់រំវិន័យតាមរបៀបវិជ្ជមាននេះ ក៏នឹងធ្វើឱ្យកុមារៗ ក្នុងប្រទេសកម្ពុជាមានអនាគតល្អទៅថ្ងៃអនាគតផងដែរ។

# បុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូនៅព្រះសហគមន៍កាតូលិក

លោកអាន ឫទ្ធីរដ្ឋ និងម៉ារី

*ព្រះសហគមន៍កាតូលិកបានប្រារព្ធពិធីបុណ្យលើកតម្កើងទុក្ខលំបាកព្រះយេស៊ូ មុនពេលព្រះអង្គទទួលជីវិតថ្មីដ៏រុងរឿងពីព្រះជាម្ចាស់ ។*



គ្រីស្តបរិស័ទលើកស្លឹករាម និងស្រែកជ័យឃោសលាន់ឮឡើង





លោកអភិបាលគីកេ ហ្វីការេដូ នៃភូមិភាគកាតូលិកបាត់ដំបងបាចទឹកព្រះពរលើស្លឹករាមនៅពេលកម្មវិធីកំពុងប្រព្រឹត្តទៅ



លោកអភិបាលគីកេ ហ្វីការេដូ និងលោកបូជាចារ្យផ្សេងទៀតធ្វើដំណើរចូលព្រះវិហារដើម្បីប្រារព្ធពិធីបុណ្យ



ពិធីបុណ្យលើកតម្កើងទុកលំបាករបស់ព្រះយេស៊ូនៅព្រះវិហារព្រះកុមារយេស៊ូនៅព្រះសហគមន៍កាូលិកបឹងទំពុន នៅរាជធានីភ្នំពេញ



ពិធីបុណ្យហែរឈើឆ្កាងនៅព្រះវិហារបឹងទំពុន ដោយហែរចេញពីគេហដ្ឋានបងស្រីឧបការគុណមកកាន់ព្រះវិហារ



លោកបូជាចារ្យ ម៉ារីយ៉ូ ហ្គេហ្វី លើកស្លឹករាមដើម្បីឧទ្ទិសក្នុងពិធីបុណ្យហែរស្លឹកនៅព្រះវិហារព្រះកុមារយេស៊ូ ដែលជាពិធីបុណ្យមួយក្នុងប្រពៃណីរបស់ព្រះសហគមន៍កាតូលិក

## បទយកការណ៍ព្រះសហគមន៍កាតូលិក

# វិទ្យាស្ថានថ្មី ក្ដីសង្ឃឹមរបស់យុវជនយុវនារី ខេត្តតាកែវ

**កែវ កញ្ញា**

មនុស្សជាងមួយពាន់នាក់ បានមកចូលរួមកម្មវិធីសម្ពោធវិទ្យាស្ថានសន្តប៉ូល ដែលស្ថិតក្នុងស្រុកអង្គតាសោម ខេត្តតាកែវ ក្រោមអធិបតីភាពរបស់លោកអគ្គអភិបាលដ៏ឧត្ដុងឧត្ដម សាលវ៉ាទ័រ ពីណាស៊ីអូ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីយឹម ឆៃលី ដែលជាប្រធានក្រុមប្រឹក្សាស្ដារអភិវឌ្ឍកសិកម្មនិងជនបទ លោកអភិបាលព្រះសហគមន៍កាតូលិក ហើយនិងភ្ញៀវជាតិ និងអន្តរជាតិជាច្រើនរូបទៀត។

លោកអភិបាលអូលីវីយេ ផ្មិតហាស្លេ ជានាយកវិទ្យាស្ថាននេះ មានប្រសាសន៍ទៅកាន់អ្នកចូលរួមក្នុងអង្គពិធីនោះថា វិទ្យាស្ថាននេះបានកសាងឡើងដើម្បីរួមចំណែកកសាង និងអភិវឌ្ឍធនធានមនុស្សឱ្យកូនសិស្សមានជំនាញផ្ទាល់ដើម្បីជួយដល់គ្រួសារក៏ដូចជាជីវភាពប្រជាជន និងអភិវឌ្ឍសង្គមជាតិ។

ក្នុងឱកាស ដ៏សែនរីករាយលោក អគ្គអភិបាលដ៏ឧត្ដុងឧត្ដមសាលវ៉ាទ័រ ពីណាស៊ីអូ មានប្រសាសន៍ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់សប្បុរសជនដែលមានចិត្តសប្បុរសក្នុងការជួយគាំទ្រ ព្រមទាំងឱ្យមានដំណើរការដល់វិទ្យាស្ថាននេះ។ លោកមានប្រសាសន៍បន្ថែមថា : "នេះគឺជាបេសកកម្មរបស់ខ្ញុំក្នុងនាមជាអគ្គរាជទូតនៃសន្តអាសនៈ ក្នុងកាជំរុញឱ្យគ្រីស្តបរិស័ទបម្រើប្រជាជនកម្ពុជា។

វិទ្យាស្ថាននេះក៏មានរួមចំណែកសហការរវាងព្រះសហគមន៍កាតូលិក និងសកលវិទ្យាល័យភូមិន្ទកសិកម្មផ្នែកកសិកម្ម ខាងបរិញ្ញាបត្រ និងបរិញ្ញាបត្ររង។ សព្វថ្ងៃនេះ វិទ្យាស្ថានសន្តប៉ូលបានក្លាយជាទីកន្លែងពិសេសដើម្បីផ្ដល់ក្ដីសង្ឃឹមដល់និស្សិតក្រីក្រ ហើយវិទ្យាស្ថាននឹងយកចិត្តទុកដាក់ចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ តាមរយៈការអប់រំនិស្សិតដោយផ្អែកលើតម្លៃសីលធម៌ជាមូលដ្ឋាន។

វិទ្យាស្ថានសន្តប៉ូល បានបង្កើតឡើងក្នុងឆ្នាំ២០០៧ ហើយបានរើទីតាំងថ្មី នឹងបានដាក់សម្ពោធឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២ ខែមីនានេះ។

វិទ្យាស្ថានថ្មីនេះ មានបង្រៀនពីរជំនាញ គឺសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា និងថ្នាក់បរិញ្ញាបត្ររងផ្នែកកសិកម្ម។ វិទ្យាស្ថានសន្តប៉ូលនេះគឺជាសាលាដំបូង នៃព្រះសហគមន៍កាតូលិក ដែលមានគោលដៅ អប់រំបណ្ដុះបណ្ដាលនិស្សិត ដោយផ្អែកលើគុណធម៌និងសីលធម៌ ដើម្បីឱ្យយុវជន-នារីអាចបំពេញតួនាទីរបស់ខ្លួន ចំពោះការអភិវឌ្ឍប្រទេសជាតិដើម្បីជម្រុញឱ្យសង្គមកម្ពុជាមានយុត្តិធម៌ និងប្រជាធិបតេយ្យឱ្យកាន់តែប្រសើរឡើង។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ក៏បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ព្រះសហគមន៍កាតូលិកក្នុងវិស័យអប់រំសិក្សា គឺជាការចូលរួមអភិវឌ្ឍនូវធនធានមនុស្ស ដើម្បីកាត់បន្ថយភាពក្រីក្រ ដែលវាស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

មកដល់ពេលនេះ វិទ្យាស្ថាន មានសិស្សទទួលវិញ្ញាបនបត្រ បរិញ្ញាបត្ររងខាងផ្នែកកសិកម្ម នៅជំនាន់ ទី១ ចំនួន ៣៩នាក់។

យុវជនយឹម វ៉ាន គឺជានិស្សិតទើបតែបញ្ចប់ការសិក្សានៅវិទ្យាស្ថានសន្តប៉ូលផ្នែកកសិកម្ម បានឱ្យដឹងថា គាត់ទទួលបានទាំងការអប់រំ និងទាំងជំនាញមួយដ៏ពិតប្រាកដ ហើយពិសេស មានការចំណាយតិចផង។ យុវជនរូបនេះ បានឱ្យដឹងថា : "ក្នុងមួយឆ្នាំ ខ្ញុំបង់សាលាតែមួយខែ ៥០០០០រៀលទេ។ តែរូបខ្ញុំបានទទួលការអប់រំល្អពុំចាញ់នៅភ្នំពេញប៉ុន្មានទេ។ វាជាការល្អប្រសើរណាស់សម្រាប់កូនកសិករដូចខ្ញុំ ដែលមានឪពុកម្ដាយចាស់ជរា ដែលមិនមានលទ្ធភាពឱ្យខ្ញុំបន្តនៅភ្នំពេញនោះ"។



Photo : L.Sovanna

April-2010.qxd 6/10/2010 2:56 PM Page 16

## ជីវិតខ្ញុំ

# “ព្រះអង្គ និងធ្វើឱ្យមានសេចក្តីពិតតាមអ្វីដែលចែងទុកមក”

**ពន**

លោកមួងរស់ ជានិស្សិតទេវវិទ្យាល័យវ័យ៣៥ឆ្នាំមកពីព្រះសហគមន៍បល្ល័ង្ក ខេត្តកំពង់ធំ ។ ជាកូនកសិករ មានបងប្អូនប្រុស៤នាក់ និងម្តាយជាស្ត្រីមេម៉ាយ ។ គ្រួសារក៏តែងជំរុញលើកទឹកចិត្តលោកស្វែងរកវិជ្ជាដើម្បីជីវិតរបស់ខ្លួននាពេលខាងមុខ ។

លោកមួងរស់បានសម្រេចចិត្តបន្តនូវការសិក្សានៅទីក្រុងភ្នំពេញនៅសាលាបណ្តុះបណ្តាលបច្ចេក-ទេសដុនបូស្កូផ្នែកអគ្គីសនី នៅឆ្នាំ១៩៩៨ ។ ក្រៅពីការសិក្សា លោកមួង រស់ មិនដែលបណ្តោយខ្លួនឱ្យចាកឆ្ងាយពីជំនឿដែលខ្លួនមានដែរ ។

រៀងរាល់សប្តាហ៏ លោករស់មានមុខងារចូលរួមរៀបចំអភិបូជានៅឯសាលាដុនបូស្កូ និងធ្វើសកម្ម-ភាពជាមួយបងប្អូន ដែលនេះគឺបានជំរុញឱ្យលោកមានចិត្តថ្វាយខ្លួនជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ។



Photo : H. Sotheary

កត្តាទាំងនេះធ្វើឱ្យលោកមួងរស់ បានចូលស្វែងយល់អំពីជីវិតអ្នកបួសក្នុងឆ្នាំ២០០៤ និងបម្រើនៅព្រះសហគមន៍បឹងទំពុនរយៈពេលមួយឆ្នាំ ។ លោកមួង រស់ និយាយដែរថា: ˝ខ្ញុំបានស្គាល់ និងធ្វើបុណ្យជ្រមុជទឹក ក្នុងឆ្នាំ២០០២ ។ ទោះបីជាក្រុមគ្រួសាររបស់ខ្ញុំមានសាសនាបីផ្សេងៗគ្នា គឺព្រះពុទ្ធសាសនាកាតូលិកសាសនានិងប្រូតេស្តង់ក៏ដោយ ។ តែយើងម្នាក់ៗពុំដែលមានការតេះដៀល ឬបំបិទសិទ្ធិបុគ្គលណាម្នាក់ឡើយ ។ ផ្ទុយទៅវិញសម្រាប់ការរស់នៅមានតែការស្វែងយល់ពីគ្នា លើកទឹកចិត្ត និងគាំទ្រអ្វីដែលជាសេចក្តីល្អនិងសេចក្តីពិតតាមជំនឿខ្លួន ។ ពីដំបូង ខ្ញុំពុំសូវទទួលបានការគាំទ្រពីម្តាយក្នុងការថ្វាយខ្លួនជាអ្នកគង្វាលក្នុងនាមព្រះយេស៊ូទេ ។ប៉ុន្តែពេលនេះ បញ្ហានេះមិនចោទមានឡើងទៀតឡើយ ត្បិតអ្វីដែលព្រះបិតាទ្រង់បានរៀបចំទ្រង់ ទ្រង់នឹងធ្វើឱ្យមានរូបរាងតាមសេចក្តីដែលបានចែងទុក˝ ។

សព្វថ្ងៃនេះ លោកមួង រស់ ជានិស្សិតឆ្នាំ៤ ផ្នែកសង្គមសាស្ត្រ និងមនុស្សសាស្ត្រនៅឯសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោករស់ បានបន្តថា ទោះបីខ្លួន គឺជានិសិត្សទេវវិទ្យាល័យ ប៉ុន្តែការល្បួងរបស់មារសាតាំង ក៏មានតាមលក្ខណៈមនុស្ស ។ ប៉ុន្តែអ្វីដែលលោកមាន និងបងប្អូនឯទៀតមាន ដូចគ្នាដែរនោះ គឺជំនឿតែមួយនៅលើព្រះត្រៃឯក គឺព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

លោកមួង រស់ពោលថា ការអធិដ្ឋាន និងជជែកជាមួយអ្នកដឹកនាំខាងផ្លូវវិញ្ញាណ ជាមាគ៌ាពិតដែលអាចឱ្យយើងម្នាក់ៗ អាចយល់បានថា អ្វីជាសម្លេងព្រះអង្គគង់នៅជាមួយ និងដឹកនាំយើង ឱ្យដើរតាមផ្លូវត្រឹមត្រូវក្នុងនាមបុត្រធីតារបស់ព្រះអង្គ ។

សព្វថ្ងៃលោករស់កំពុងបម្រើនៅព្រះសហគមន៍សន្តីម៉ារី ម៉ាដឺឡា នៅស្វាយប៉ាក ទីក្រុងភ្នំពេញ និងកំពុងត្រៀមខ្លួនក្លាយជាអ្នកគង្វាលដ៏សប្បុរសក្នុងរយៈពេល ៤ឆ្នាំ ខាងមុខទៀត ។

## ប្រតិទិនអភិបូជា

- **ភាសាខ្មែរ** : ព្រះវិហារសន្តយ៉ូសែបភ្នំពេញ (០១២ ៧៨២ ២៤១) ថ្ងៃច័ន្ទ-សៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក និងម៉ោង៤រសៀល។
  -កំពង់សោម (០១៦ ៨៤០ ៥៤០) ថ្ងៃច័ន្ទ ថ្ងៃពុធ និងថ្ងៃសុក្រ : ល្ងាចម៉ោង៥។ ថ្ងៃអង្គារ ថ្ងៃព្រហស្បតិ៍ និងថ្ងៃសៅរ៍ : ព្រឹកម៉ោង៦។ ថ្ងៃអាទិត្យ : ម៉ោង ៨ព្រឹក។
  -សៀមរាប (០៦៣ ៩៦៥ ២៨០) ថ្ងៃអាទិត្យ : ម៉ោង៧:៣០ព្រឹក។ ថ្ងៃច័ន្ទ-ថ្ងៃព្រហស្បតិ៍ : ព្រឹក ៦:៣០ម៉ោង។ ថ្ងៃសុក្រ : ម៉ោង ៦:៣០ល្ងាច។
  -បាត់ដំបង (ពេទ្យយាយជី) ថ្ងៃអាទិត្យ : ម៉ោង ៨:០០ព្រឹក។ ថ្ងៃច័ន្ទ : ល្ងាច៦:០០។ ថ្ងៃអង្គារ-សុក្រ : ម៉ោង៦:១៥ ព្រឹក។
- **Français** : 1er et 3ème Samedi du mois à 5:30pm ; 2ème et 4ème Dimanche du mois à 11:00am; à l'église de St. Joseph, #1788B, RN5, PP.
- **English** : - Phnom Penh : Sunday at 10: 00 am; at St. Joseph Church (#1788B, NR5, PP); Saturday at 5: 00 pm, at World Vision Cambodia (#2 St 71, PP); - Sihaknouk Ville : Sunday at 5:00 pm; # Catholic Church St.12 13 Mattapheap; H/P: 016 840 540 (Fr. Werachai); - Siem Reap : Saturday at 6:30 pm; #Catholic Church, No 027 East River Side Street. - Battambang : Saturday: at 6:00 pm at Battamabang Church (Pet Yeaychi), Rumchek 1, Rattanak, H/P: 012 911 147 (Fr. Totet).

April-2010.qxd 6/10/2010 2:56 PM Page 17





Photo : S. Philong

# យុវសិល្បករខ្មែរ៥រូបទទួលបានការទទួលស្គាល់ពីប្រទេសបារាំង

**ខាន់ ភីរម្យ**

យុវសិល្បករខ្មែរនាជំនាន់ក្រោយយ៉ាងហោចណាស់ប្រាំនាក់ ត្រូវបានទទួលស្គាល់ស្នាដៃគូរគំនូរជាលក្ខណៈអន្តរជាតិ ពិសេសពីប្រទេសបារាំង។

បើយោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់មជ្ឈមណ្ឌលវប្បធម៌បារាំងបានឱ្យដឹងថា ពួកគេទាំង៥នាក់នេះ មានលោកអេមីល កុល លោកពៅ ទី លោកចាន់ ពិសី លោកនង សាកល និងលោកជា សិរីរតន៍។ ពួកគេទាំងបួននាក់នេះ គឺជាយុវសិស្សផ្នែកសិល្បៈនៅអង្គការហ្វាពន្លឺសិល្បៈ ដែលជាអង្គការមនុស្សធម៌មួយមានទីស្នាក់ការនៅខេត្តបាត់ដំបង។

ប្រភពព័ត៌មានដដែលនោះ បានឱ្យដឹងថា ស្នាដៃរបស់ពួកគេ ត្រូវបានគេយកមកដាក់តាំងពិព័រណ៍ជាសាធារណៈកាលពីថ្ងៃទី១៨ ខែមីនា នៅក្នុងមជ្ឈមណ្ឌលវប្បធម៌បារាំង ហើយត្រូវបានគេជ្រើសរើសបញ្ជូននិងប្រែក្លាយទៅជាស្នាដៃគំនូរជីវចល។

ស្នាដៃសិល្បៈ ដែលពួកគេបានបញ្ចេញជាលក្ខណៈក្រុមនេះ ត្រូវបានគេដាក់ឈ្មោះថា "ទំពាំងស្នងឫស្សី" ដោយសារតែពួកគេគឺជាវិចិត្រករវ័យក្មេង ប៉ុន្តែមានស្នាដៃល្អ។ ពួកគេក៏បានទទួលជោគជ័យនៅលើស្នាដៃសិល្បៈនេះ គឺដោយសារតែការប្រើប្រាស់គំនិតច្នៃប្រឌិតរបស់ពួកគេផ្ទាល់ជាមួយនឹងឧបករណ៍ដ៏សាមញ្ញ ដូចជា ជក់ និងខ្មៅដៃធម្មតាៗតែប៉ុណ្ណោះ។ គំនូរជីវចលដែលគេនឹងផលិតចេញពីស្នាដៃនេះ ជាប្រភេទគំនូរជីវចលប្រភេទខ្លីមួយប្រភេទ។

ប្រភពដដែលនោះ បានឱ្យដឹងទៀតផងដែរថាស្នាដៃរបស់ពួកគេកើតឡើងក្រោយពេល ដែលពួកគេបានខិតខំ អស់រយៈពេល១ឆ្នាំ ដោយចាត់តាំងរចនាសម្ព័ន្ធការងារជាក្រុម និងមានស្វ័យភាពថវិកាផងដែរ។

ពួកគេទាំងប្រាំនាក់នេះ ត្រូវបានបង្ហាត់បង្រៀនដោយលោកអ៊ឹង ភូសេរ៉ា ដែលជាវិចិត្រករខ្មែរដ៏ល្បី នៅប្រទេសបារាំង។

ស្នាដៃរបស់ពួកគេទាំងប្រាំនាក់នេះ នឹងត្រូវអង្គការ ហ្វាពន្លឺសិល្បៈ ចងក្រងធ្វើជាសៀវភៅអាល់ប៊ុមគំនូរចំនួន២ក្បាល ទុកបម្រើការស្រាវជ្រាវ ទៅថ្ងៃអនាគត ដល់យុវនិស្សិតវ័យក្មេងឯទៀតៗ។

សូមបញ្ជាក់ថា ក្រៅពីស្នាដៃរបស់យុវសិល្បករវ័យក្មេងនេះចេញនោះ ចាប់ពីពាក់កណ្តាលខែមីនារហូតដល់ចុងខែមីនា មជ្ឈមណ្ឌលវប្បធម៌បារាំង មានរៀបចំបញ្ចាំងខ្សែភាពយន្តជាច្រើនទៀតផងដែរ។

## អំណាន

### រឿងព្រះនាងកំប៉ោង



គឺជារឿងទើបនឹងចេញផ្សាយ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយដំរីស។ ខុសអំពីរឿងព្រេងប្រជាប្រិយដែលគេចម្លងតៗគ្នា ហើយបានដាក់តាំង លក់ពាសពេញបណ្ណាគារ និងតូបលក់សៀវភៅនានា រឿងព្រះនាងកំប៉ោង គឺតំណាងឱ្យការបង្កើតថ្មី និងច្នៃប្រឌិត។ បើនិយាយឱ្យខ្លី រឿងនេះជាសិល្បៈ និងវប្បធម៌ពិតប្រាកដមួយ។

ព្រះនាងកំប្លង់ជាបុត្រីស្តេច។ នាងមានរូបល្អនិងមានគូដណ្តឹងស្លូតបូតម្នាក់។ តែអ្វីៗត្រូវបានផ្លាស់ប្តូរ។ នាងប្រែជាមានរូបរាងកំប៉ោង ធាត់អាក្រក់អាក្រី ដោយសារប្អូនជីដូនមួយ ដែលច្រណែននឹងភាពថ្កុំថ្កើងរបស់នាង បានដាក់ថ្នាំក្នុងផ្លែឈើឱ្យកំប្លង់សោយ...

ព្រះនាងកំប៉ោង ត្រូវចាកចេញពីជីវិតចាស់។ បន្ទាប់ពីឆ្លងកាត់ឧបសគ្គជាច្រើនមក កំប៉ោងចេះអ្វីៗថ្មី ក្នុងជីវិត: ការសណ្តោស ការរៀនរង់ចាំ ការជួយជីវិតអ្នកដទៃ...

រឿងនេះនិពន្ធដោយ លោកពេជ្រ ព្រឿង និងត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០១០ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយដំរីស ហើយមាន ២៣ទំព័រ តម្លៃ ៣៥០០រៀល ។

### រឿង សត្វកំរោអង្គ




យើងចូលចិត្តរឿងភ័យរន្ធត់ កាន់តែគួរឱ្យខ្លាច កាន់តែចង់ដឹង។ តែតើយើងចង់ដឹងពីអ្វី? ចង់ដឹងថាសភាវៈអធិធម្មជាតិ មានឬអត់ ? ចុះបើមានវិញ?

តួអង្គរឿងនេះមានអារម្មណ៍ថា មានអ្វីមួយរស់នៅជាមួយនឹងគាត់គ្រប់ពេលវេលា ទាំងយប់ថ្ងៃ។ យប់ខ្លះ គាត់មានអារម្មណ៍ថា វាថែមទាំងមកច្របាច់កគាត់ផង។ គាត់ខ្លាចវា។ គាត់ចង់សម្លាប់វា។ តែគាត់មិនប្រាកដក្នុងចិត្តថាតើវាហ្នឹងជាអ្វី... តើជាសត្វកំរោអង្គ?

នេះគឺជាប្រភេទរឿងបែបស្រមើលស្រមៃ។ វាពុំមែនជារឿងបែបអច្ឆរិយៈ ឬអភិនិហារនោះទេ ព្រោះមិនមានខ្មោចព្រាយបិសាចក្នុងរឿងនេះឡើយ។ ប៉ុន្តែវាធ្វើឱ្យអ្នកអានខ្លាច... ទាំងមិនដឹងថា ខ្លួនកំពុងតែខ្លាចអ្វី...។ ហើយនៅទីបញ្ចប់រឿង ទាំងអ្នកនិពន្ធ ទាំងអ្នកអាន សុទ្ធតែមិនច្បាស់ថា មានវត្ថុរូបី ឬអរូបី ពិតប្រាកដនោះឡើយ។

រឿងនេះនិពន្ធដោយហ្គី ដឺ ម៉ូប៉ាសង់ បកប្រែជាភាសាខ្មែរដោយលោកគ្រីស្តូហ្វ ម៉ាកកេ និងនិស្សិតនៅដេប៉ាតឺម៉ង់ ភាសាបារាំង និងមានកម្រាស់ ១១៦ទំព័រ។

**ហួត សុជាតា**

April-2010.qxd 6/10/2010 2:56 PM Page 18

## ប្រវត្តិសាស្ត្រ

# កូរ៉េខាងជើង ប្រទេសមានបញ្ហាអាវុធនុយក្លេអ៊ែរ

**ជាត សំភី**

មួយថ្ងៃក្រោយអំពីការចុះចាញ់របស់ជប៉ុននៅក្នុងសង្គ្រាមលោកលើកទីពីរនៅថ្ងៃទី១៥ សីហា ឆ្នាំ១៩៤៥ លោកគីម អ៊ីលស៊ុង ដែលបានដឹកនាំកងទ័ពបដិវត្ត ប្រជាជនកូរ៉េ (ARPC) ក្នុងការប្រឆាំងរបស់កូរ៉េទៅនឹងការត្រួតត្រារបស់ជប៉ុន បានក្លាយជាមេដឹកនាំសំខាន់របស់ប្រទេស ក្នុងនាមជាអគ្គលេខា បក្សពលករកូរ៉េ ដែលមានប្រភពមកពីការរលាយចូលគ្នារវាង បក្សកុម្មុយនីស្ត និងគណបក្សប្រជាធិបតេយ្យថ្មីរបស់កូរ៉េ ។



### កូរ៉េខាងជើង

ហៅតាមផ្លូវការ សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ គឺជារដ្ឋដែលគ្របដណ្តប់ពាក់កណ្តាលខាងជើងនៃជ្រោយកូរ៉េ និងជាចំនុចល្បីសាននៃទ្វីបអាស៊ី។ ប្រទេសនេះមានព្រំប្រទល់ជាប់នឹងប្រទេសចិន (មានព្រំដែនរួមចម្ងាយ ១៤១៦គម) និងជាមួយរុស្ស៊ី (ព្រំដែនរួម ១៩គម) នៅភាគខាងជើង ព្រមទាំងមានព្រំដែនជាប់សាធារណរដ្ឋកូរ៉េនៅភាគខាងត្បូង (២៣៨គមព្រំដែនរួម)។ ព្រំដែនខាងត្បូងនេះត្រូវបានបង្កើតឡើងដោយតំបន់គ្មានកងទ័ព(DMZ)ដែលតាមការពិត គឺពោរពេញដោយកងកម្លាំងប្រដាប់អាវុធ ហើយដែលត្រួតពិនិត្យឃើញជាសរុប គឺមានកងកម្លាំងជាងមួយលាននាក់។ ជប៉ុនជាអ្នកជិតខាងសមុទ្រត្រូវបានខណ្ឌផ្តាច់ពីកូរ៉េខាងជើងដោយសមុទ្រជប៉ុន។ ឈ្មោះផ្លូវការកូរ៉េមានន័យថា ប្រទេសនៃពេលព្រលឹមស្រស់បស់ ឬបកស្រាយមិនសូវចំថា ជាប្រទេសនៃពេលព្រលឹមស្ងប់ស្ងាត់។

បន្ទាប់ពីសង្គ្រាមកូរ៉េ ដែលវាបង្កឱ្យមនុស្សស្លាប់ជាងមួយលាននាក់នៅភាគខាងជើង កូរ៉េខាងជើងបានពង្រឹងពង្រីកឧស្សាហកម្មរបស់ខ្លួនយ៉ាងរហ័ស និងព្យាយាមឈានទៅរកភាពឯករាជ្យម្ចាស់ការលើនយោបាយសេដ្ឋកិច្ច និងយោធា ឱ្យស្របតាមគោលការណ៍នៃមនោគមវិជ្ជាបដិវត្តន៍ថ្មីរបស់កូរ៉េ ។ ដោយអវត្តមានសន្ធិសញ្ញាសន្តិភាពចាប់តាំងពីការចប់សង្គ្រាមកូរ៉េនៅឆ្នាំ១៩៥៣ មកភាពតានតឹងលើឆាកអន្តរជាតិ បានលាបពណ៌ ដល់នយោបាយក្រៅប្រទេសរបស់កូរ៉េខាងជើង ។ នៅថ្ងៃទី ២១ មករា ឆ្នាំ១៩៦៨ ភ្នាក់ងារកូរ៉េខាងជើង បានវាយប្រហារលើវិមានប្រធានាធិបតីរបស់កូរ៉េខាងត្បូងនាទីក្រុងសេអ៊ូល ។ នាវាចារកម្មអាមេរិក Pueblo ត្រូវបានឃាត់ទុកក្នុងដែនទឹកកូរ៉េខាងជើងក្នុងឆ្នាំដដែល ។




Photos : DR

នៅក្នុងកិច្ចការផ្ទៃក្នុង ប្រមុខដឹកនាំ គីម ជុងអ៊ីល កូនរបស់ប្រធានាធិបតីគីម អ៊ីលស៊ុង ត្រូវបានគេរៀបចំឱ្យស្នងបន្តឪពុកចាប់តាំងពីឆ្នាំ១៩៨០ ។ បន្ទាប់អំពីការស្លាប់របស់លោកគីម អ៊ីលស៊ុង នៅ១៩៩៤និងបន្ទាប់ពីការកាន់ទុក្ខថ្នាក់ជាតិរយៈពេលបីឆ្នាំ ស្របតាមប្រពៃណីកូរ៉េបន្ទាប់ពីស្លាប់របស់ឪពុក ។ លោកគីម ជុងអ៊ីល ក៏បានស្នងជាផ្លូវការ នូវតំណែងខ្ពស់បំផុតរបស់រដ្ឋនៅឆ្នាំ១៩៩៧ ។

នៅថ្ងៃទី៣១ សីហា ឆ្នាំ១៩៩៨ កូរ៉េខាងជើងក៏មានគោលបំណងបង្ហោះនូវផ្កាយរណបសិប្បនិមិត្តមួយ បន្ទាប់មកមីស៊ីល Taepodong-I ។ គ្មានដានផ្កាយរណបណាដែលត្រូវ បានគេរកឃើញទេ ទោះការផ្សព្វផ្សាយជាផ្លូវការបង្ហាញអំពីភាពជោគជ័យនៃការបង្ហោះនេះក៏ដោយ ។ អ្នកជំនាញអាមេរិកក៏បានស្មានថា ផ្នែកខាងខ្ពស់បំផុតនៃមីស៊ីលបានធ្លាក់ខូចខាតមុនពេលដាក់ចុះក្នុងគន្លងតារាវិថី ។

មេដឹកនាំគីមជុងអ៊ីល លើកទឹកចិត្តនូវវិធានការសេរីនិយមផ្នែកសេដ្ឋកិច្ចតាំងតែពីឆ្នាំ២០០២ ដើម្បីពង្រឹងសមត្ថភាពយោធារបស់ប្រទេស ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៦ កូរ៉េខាងជើងក៏បានប្រកាសសាកល្បងអាវុធនុយក្លេអ៊ែរ លើកទីមួយរបស់ខ្លួនដែលសកម្មភាពនេះបានបង្កើតភាពតានតឹងចំពោះសហគមន៍អន្តរជាតិ ។

April-2010.qxd 6/10/2010 2:56 PM Page 19

# អធិប្បាយព្រះបន្ទូលថ្ងៃអាទិត្យ



**អ្នកនាំសារខែមេសា ២០១០- ដោយលោកគ្រូដួង សាខឡ**

**ថ្ងៃបុណ្យព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង (ថ្ងៃទី០៤ ខែមេសា)** *លូកា ២៤,១៣-៣៥*

ថ្ងៃនេះជាបុណ្យចម្លងជាបុណ្យធំជាងគេនៅក្នុងគ្រីស្តសាសនាយើង ។ ក្នុងអត្ថបទនេះ យើងសង្កេតឃើញថា: "ព្រះយេស៊ូដែលទទួលព្រះជន្មថ្មីដ៏រុងរឿងគង់នៅជាមួយសាវ័ក ប៉ុន្តែគេទាំងពីរនាក់មិនស្គាល់ព្រះអង្គសោះ ។ នៅពេលព្រះអង្គបកស្រាយសេចក្តីដែលមានចែងទុកក្នុងព្រះគម្ពីរ គេរំភើបចិត្តយ៉ាងខ្លាំង តែគេនៅមិនស្គាល់ព្រះអង្គដដែល ។ លុះពេលព្រះអង្គកាច់នំបុ័ងប្រទានទៅគេ ស្រាប់តែភ្នែកគេភ្លឺឡើង គេស្គាល់ព្រះអង្គ ។ ប៉ុន្តែព្រះអង្គបាត់ពីមុខគេទៅ ។ គ្រីស្តបរិស័ទគឺជាអ្នកផ្ញើជីវិតលើព្រះយេស៊ូសព្វថ្ងៃ ទោះបីយើងមើលព្រះយេស៊ូ ដោយភ្នែកពុំឃើញក៏ដោយ ក៏យើងជឿថា ព្រះអង្គដែលទទួលព្រះជន្មដ៏រុងរឿងពីព្រះបិតា គង់នៅជាមួយយើង និងមនុស្សឯទៀតៗដែរ ហើយព្រះអង្គបំប្រែចិត្ត យើងទាំងអស់គ្នាឱ្យស្គាល់តម្លៃនៃជីវិតផង ។ **សូមបងប្អូនរកមើលសញ្ញាផ្សេងៗពីវត្តមានព្រះយេស៊ូគង់នៅក្នុងព្រះសហគមន៍ និងក្នុងចំណោមមនុស្សឯទៀតៗសព្វថ្ងៃ !**

**អាទិត្យទី២ ក្នុងរដូវបុណ្យចម្លង (ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១០)** *យ៉ូហាន ២០, ១៩-៣១*

ក្នុងអត្ថបទថ្ងៃនេះ ព្រះយេស៊ូដែលទទួលព្រះជន្មដ៏រុងរឿងពីព្រះបិតាយាងទៅប្រទានសេចក្តីសុខសាន្តដល់ពួកសាវ័ក ដែលភ័យខ្លាចឱ្យគេមានអំណរសប្បាយ ។ ព្រះអង្គក៏ប្រទានព្រះវិញ្ញាណដល់គេ និងចាត់គេឱ្យទៅលើកលែងទោសដល់អ្នកឯទៀតៗផង ។ គ្រីស្តបរិស័ទយើងសព្វថ្ងៃ ក៏ដូច្នោះដែរ ក្នុងឋានៈជាសាក្សីរបស់ព្រះគ្រីស្ត ទោះបីយើងជួបទុក្ខលំបាក ការប្រមាថ ឬប្រថុយប្រថាននឹងសេចក្តីស្លាប់ក៏ដោយ ក៏យើងមានអំណរសប្បាយម្យ៉ាងដែរ ពីព្រោះដឹងថា ព្រះគ្រីស្តគង់នៅជាមួយខ្លួន ។ ព្រះអង្គប្រទានព្រះវិញ្ញាណជាកម្លាំងនៃសេចក្តីស្រឡាញ់ឱ្យខ្លួនអាចស្រឡាញ់មនុស្សឯទៀតៗ និងក៏ណែនាំគេឱ្យស្គាល់សេចក្តីស្រឡាញ់របស់ព្រះបិតាតាមរយៈព្រះយេស៊ូ ។

**សូមបងប្អូនរកមើលទីសម្គាល់ផ្សេងៗ ដែលជាសញ្ញាអំពីវត្តមានព្រះយេស៊ូប្រទានសេចក្តីសុខសាន្ត និងការលើកលែងទោសក្នុងការរស់នៅសព្វថ្ងៃ !**

**អាទិត្យទី៣ នៃបុណ្យចម្លង (ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១០)** *យ៉ូហាន ២១,១-១៩*

ក្នុងអត្ថបទនេះ លោកសិលា និងសាវ័កឯទៀតៗទៅរកត្រី ប៉ុន្តែពេញមួយយប់រកមិនបានសោះ ។ ព្រះយេស៊ូបង្ហាញព្រះអង្គ និងប្រាប់ពួកគេឱ្យទម្លាក់អួនទៅខាងស្តាំ ស្រាប់តែមានត្រីជាប់ជាច្រើន ។ លុះពេលបរិភោគអាហាររួច ព្រះយេស៊ូសួរទៅលោកសិលាបីដងថា តើគាត់ស្រឡាញ់ព្រះអង្គឬទេ? លោកសិលាក៏ឆ្លើយបីដងថា គាត់ស្រឡាញ់ព្រះអង្គណាស់ ។ ព្រះយេស៊ូបញ្ជាក់ទៅគាត់បីដងថាសូមឱ្យគាត់មើលថែហ្វូងចៀមរបស់ព្រះអង្គផង ។ ចំពោះយើងសព្វថ្ងៃការចាប់ត្រីជានិមិត្តរូបនៃការប្រកាសដំណឹងល្អ ។

ម្យ៉ាងទៀតអត្ថបទនេះ ក៏ប្រាប់យើងពីកិត្តិយសរបស់អ្នកបម្រើព្រះសហគមន៍ដែរ ។ ទោះលោកសិលាធ្លាប់បដិសេធព្រះយេស៊ូបីដងក្តី ក៏ព្រះអង្គនៅប្រោសលោក ឱ្យទៅជាអ្នកបម្រើដ៏សំខាន់ម្នាក់ដែរ ។ ដោយមានព្រះវិញ្ញាណគង់នៅជាមួយ យើងម្នាក់ៗ គឺជាអ្នកបម្រើដ៏ពិសេស ។ សូមកុំអស់សង្ឃឹម ។ សម្រាប់ព្រះសហគមន៍កាតូលិកលោកអភិបាលព្រះសហគមន៍ក្រុងរ៉ូមជាអ្នកបន្តមុខងារដ៏ពិសេសពីលោកសិលាមក ។

**តើសព្វថ្ងៃ ខ្ញុំស្រឡាញ់ព្រះយេស៊ូ និងមានទំនាក់ទំនងជាមួយព្រះអង្គយ៉ាងណា ?**

**អាទិត្យទី៤ នៃបុណ្យចម្លង (ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១០)** *យ៉ូហាន ១០,២៧-៣០*

**"ទិវា សូមឱ្យម្នាក់ៗទទួលស្គាល់ការត្រាស់ហៅរបស់ខ្លួន"**

អត្ថបទថ្ងៃនេះ ព្រះយេស៊ូបញ្ជាក់អំពីកិច្ចការរបស់ព្រះអង្គ ។ តាមសម្ព័ន្ធមេត្រីចាស់ ព្រះជាម្ចាស់ជាគង្វាលដែលណែនាំប្រជារាស្ត្ររបស់ព្រះអង្គ ។ ស្តេចនិងអ្នកណែនាំសាសនានៃជនជាតិយូដា គេណែនាំប្រជារាស្ត្រក្នុងនាមព្រះជាម្ចាស់ តែគេមិនធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ គ្រីស្តបរិស័ទជឿថា ព្រះយេស៊ូជាគង្វាលដ៏ប្រសើរ ព្រះអង្គយាងមកណែនាំប្រជារាស្ត្រនៃព្រះជាម្ចាស់ និងមនុស្សទាំងអស់ជំនួសគេ ។ ព្រះយេស៊ូព្រួយព្រះហឫទ័យដោយឃើញយើងខ្វះជំនឿ ព្រះអង្គបញ្ជាក់ថា ព្រះអង្គយាងមកពីព្រះបិតា ព្រះអង្គ និងព្រះបិតាគឺតែមួយ ។ ព្រះអង្គណែនាំមនុស្សទាំងអស់ឱ្យទាក់ទងជាមួយព្រះបិតាវិញ ហើយការពារមិនឱ្យយើងឃ្លាតឆ្ងាយពីព្រះបិតា ដែលជាកំពូលនៃសុភមង្គលគ្រប់យ៉ាងនោះឡើយ ។

**ក្នុងទិវាឱ្យម្នាក់ៗទទួលស្គាល់ការត្រាស់ហៅរបស់ខ្លួននេះ តើខ្ញុំស្តាប់ឮព្រះសូរសៀងដែលត្រាស់ហៅខ្ញុំឱ្យផ្ញើជីវិតលើព្រះអង្គយ៉ាងណា ?**

## ព័ត៌មាន

### លោកអភិបាលជាតិស្រីលង្កា អំពាវនាវឱ្យមានការបោះឆ្នោតដោយសេរី និងគ្មានហិង្សា

បើតាមសេចក្តីរាយការណ៍កាលពីថ្ងៃទី៧ មេសា របស់សារព័ត៌មានយូខែន បានឱ្យដឹងថា លោកអភិបាលស្រីលង្កា ម៉ាល់ខម រ៉ានជីត បានអំពាវនាវសម្រាប់ការបោះឆ្នោតជាសកលនៅថ្ងៃទី៨ខែមេសា ឱ្យមានសេរីភាព និងគ្មានអំពើហិង្សា ។ នេះគឺជាការបោះឆ្នោតជ្រើសរើសសមាជិកសភា១៩៦នាក់ នៅក្នុងចំណោមអ្នកឈរឈ្មោះ ៧៦២០នាក់ ដែលមកពី ៣៦គណបក្សនៅទូទាំងប្រទេស ។

តាមរបាយការណ៍មួយ លោក អភិបាលជាតិស្រីលង្កា បានអំពាវនាវទៅកាន់គណៈកម្មាធិការបោះឆ្នោត ឱ្យបំពេញមុខងារខ្លួនប្រកបដោយភាពត្រឹមត្រូវ និងក៏ទទួលខុសត្រូវខ្ពស់ ។ ក្រៅពីនេះលោកអភិបាល ក៏បានអំពាវនាវឱ្យមានស្តង់ដារក្រមសីលធម៌ខ្ពស់ ដើម្បីរក្សាស្ថានការណ៍បោះឆ្នោត ជាពិសេសនៅតាម មណ្ឌលបោះឆ្នោតនីមួយៗ និងការប្រកាសលទ្ធផលឆ្នោតឱ្យមានតម្លាភាព ធានានូវភាពទុកចិត្ត និងជឿជាក់ ។

លោកអភិបាលក៏បានបន្ថែមថា អ្នកបោះឆ្នោតត្រូវតែមានការទទួលខុសត្រូវខ្ពស់ និងតម្លាភាពនៅក្នុងការបោះឆ្នោត ដែលលទ្ធផល នឹងជះឥទ្ធិពលដល់មនុស្សភាគច្រើន ។ អ្នកបោះឆ្នោត គួរតែជាមនុស្ស ដែលគោរពដល់អ្នកដទៃ ទោះបីជាបុរស-ស្ត្រី មានក្រមសីល ធម៌ មានអាយុ ឬក៏សាសនាក៏ដោយ ។ ការរួបរួមភាពស្មើគ្នា និងការសហការគ្នានៅគ្រប់ស្ថាប័នក្នុងសង្គម គឺគប្បីជាកម្មវត្ថុគន្លឹះសម្រាប់រដ្ឋាភិបាលនាពេលអនាគត ។


Photo : Ucanews

**ជុង យ៉ត**

April-2010.qxd 6/10/2010 2:56 PM Page 20

## “ជៀសពីគ្រឿងញៀន ដើម្បីការពារជីវិតអ្នក”

# លេខទូរស័ព្ទដែលត្រូវហៅ បន្ទាន់

*ករណីសង្ស័យគ្រុនផ្ដាសាយថ្មី A/H1N1 :

១១៥ / ០១២ ៤៨៨ ៩៨១ / ០៨៩ ៦៦៩ ៥៦៧។

*មណ្ឌលកែប្រែអ្នកញៀនគ្រឿងញៀន :

០១២ ៨១២ ១១៧ / ០១៥ ៨៩៣ ៩៩៩។

*រថយន្តសង្គ្រោះបន្ទាន់ :

-ភ្នំពេញ ០២៣ ៧២៤ ៨៩១។ -សៀមរាប ០៦៣ ៧៦១ ១១៩។

*ប៉ូលីសប្រឆាំងការជួញដូរស្ត្រី :

១១៧

# ល្បែងកំសាន្ត

**រកផ្លូវ**

សូមប្រិយមិត្តជួយគូសរកផ្លូវឱ្យកូនកណ្ដុរនេះបានទៅស៊ីផ្លែប៉ោមដ៏ឆ្ងាញ់នេះផង។



Photo : jeux-loisirs-enfants

## ការងារប្រចាំខែ

- ថ្ងៃទី០១ មេសា ឆ្នាំ២០១០ : ពិធីលាងជើងនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូចនៅភ្នំពេញ វេលាម៉ោង៥រសៀល។
- ថ្ងៃទី០១ មេសា : ប្រជុំអន្តរនិកាយដែលមានការចូលរួមប្រមាណ៣០នាក់ និងរៀបចំធ្វើឡើងនៅព្រះសហគមន៍កាតូលិកកំពង់ចាម។
- ថ្ងៃទី០២ មេសា : ពិធីដើរឈើឆ្កាង និងពិធីគោរពព្រះឈើឆ្កាង នៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច វេលាម៉ោង៨ព្រឹក និងម៉ោង ៥រសៀល។
- ថ្ងៃទី០២ មេសា : ពិធីជ្រមុជទឹកឱ្យដល់គ្រីស្តបរិស័ទ ចំនួន១៤នាក់ នៅព្រះសហគមន៍កាតូលិកបាត់ដំបង។
- ថ្ងៃទី០៣ មេសា : រាត្រីបុណ្យចម្លងនៅព្រះសហគមន៍កាតូលិកផ្សារតូច។
- ថ្ងៃទី០៣ មេសា : ពិធីជ្រមុជទឹកដល់គ្រីស្តបរិស័ទ ចំនួន ៣នាក់ នៅព្រះសហគមន៍កាតូលិកព្រែកប្រស់ តំបន់ខេត្តកំពត។
- ថ្ងៃទី០៧ មេសា : ដំណើរកំសាន្តរបស់អ្នកភូមិរលាកខេត្តកំពង់ចាម មកកាន់ភ្នំពេញ។
- ថ្ងៃទី០៧ មេសា : ពិធីរំឭកខួប១០០ឆ្នាំនៅព្រះសហគមន៍កាតូលិកតាអំ ខេត្តសៀមរាប។
- ថ្ងៃទី០៩-១០ មេសា : ពិធីជំហានទី២ និងពិធីជ្រមុជទឹកដល់គ្រីស្តបរិស័ទ ចំនួន៤៤នាក់ ដែលរៀបចំធ្វើនៅព្រះសហគមន៍កាតូលិកតំបន់សៀមរាប តាអំ និងព្រែកទាល់ នៅក្នុងភូមិភាគបាត់ដំបង។
- ថ្ងៃទី១០ មេសា : ការចែកអំណោយដល់គ្រួសារក្រីក្រ ចំនួន១០០គ្រួសារ ដែលមកពីជុំវិញនៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ហៅផ្សារតូច រាជធានីភ្នំពេញ។
- ថ្ងៃទី១៣ មេសា : ចូលឆ្នាំប្រពៃណីជាតិ។
- ថ្ងៃទី១៣ មេសា : ពិធីសម្ពោធព្រះវិហារនៅក្តុលលើ ភូមិភាគកំពង់ចាម។
- ថ្ងៃទី១៦ មេសា : ពិធីរំឭកខួបអនុស្សាវរីយ៍ចំនួន២ឆ្នាំ នៅភ្នំព្រះនាងម៉ារីនៅទន្លេមេគង្គ ដែលរៀបចំឡើងនៅព្រះសហគមន៍អរិយក្សត្រ។
- ថ្ងៃទី២៨ មេសា : ពិធីសច្ចាប្រណិធានរបស់បងស្រីសង្វាត និងបងស្រីថាវីន នៅក្រុមគ្រួសារបងស្រីស្រលាញ់ឈើឆ្កាង ដែលរៀបចំនៅព្រះសហគមន៍កាតូលិកកំពង់ចាម។
- ថ្ងៃ២៩ មេសា : ប្រជុំគ្រូអប់រំជំនឿថ្មីចំនួន១៥នាក់នៅព្រះសហគមន៍កាតូលិកកំពង់ចាម។